# រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ
# ឆ្នាំ២០១៩-២០២៥

«ភាពជឿទុកចិត្ត ប្រសិទ្ធភាព ការប្រកួតប្រជែង និងការសន្សំសំចៃ»

**បានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា**

**នាថ្ងៃពុធ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២**

**ត្រូវនឹងថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩**

# មុខកថា

នៅពាក់កណ្ដាលទសវត្សរ៍ទី៨០ កម្ពុជាបានធ្វើការកែទម្រង់ជាបណ្ដើរៗឆ្ពោះទៅកាន់សេដ្ឋកិច្ចទីផ្សារ ហើយបានពុះពារឆ្លងកាត់គ្រប់ឧបសគ្គនៅលើកំណាត់ផ្លូវដ៏លំបាកនិងវែងឆ្ងាយ រហូតឈានមកដល់ចំណុចរបត់នៃការកែទម្រង់ឥតថយក្រោយនៅឆ្នាំ១៩៨៩ ហើយបានបន្តបោះជំហានទៅមុខកាន់តែលឿននិងស្វាហាប់ថែមទៀតនាពេលបច្ចុប្បន្ន។ ចាប់ពីឆ្នាំ១៩៩៣មក រាជរដ្ឋាភិបាលបានចាប់ផ្ដើមអនុវត្តកម្មវិធីកែទម្រង់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងរចនាសម្ព័ន្ធសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ សំដៅពង្រឹងប្រព័ន្ធអភិបាលកិច្ចល្អនៃការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច, ការកែលម្អប្រព័ន្ធថវិកា ការពង្រឹងការគ្រប់គ្រងលទ្ធកម្មសាធារណៈ, ការធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធគ្រប់គ្រងសារពើពន្ធ, ការកែលម្អប្រព័ន្ធគណនេយ្យសាធារណៈ ប្រព័ន្ធត្រួតពិនិត្យនិងសវនកម្ម និងការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ទន្ទឹមនឹងការខិតខំយ៉ាងសកម្មក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងពិភពលោក។

ជាលទ្ធផល នៃការកែទម្រង់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស៊ីជម្រៅនេះក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំជាង៧ភាគរយ នៃផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំ ដែលអនុញ្ញាតឱ្យកម្ពុជាអភិវឌ្ឍលើគ្រប់វិស័យ។ ប៉ុន្តែ សមិទ្ធផលនៃការអភិវឌ្ឍរបស់កម្ពុជាជាងពីរទសវត្សរ៍នេះនៅមិនអាចធ្វើឱ្យយើងស្កប់ស្កល់នៅឡើយទេ, ក្នុងនាមជាប្រមុខរាជរដ្ឋាភិបាល ខ្ញុំមានបំណងប្រាថ្នា "ប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ តាមរយៈការកសាងសង្គមមួយដែលមានសុខសន្តិភាព ស្ថិរភាព គោរពគោលការណ៍ប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌"។ ដើម្បីសម្រេចបានតាមបំណងប្រាថ្នានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយនិងយុទ្ធសាស្ត្រនៃការកែទម្រង់លើគ្រប់វិស័យជាបន្តបន្ទាប់។

ជាក់ស្ដែង, កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤ ខ្ញុំបានដាក់ចេញនូវរបៀបវារៈគោលនយោបាយកែទម្រង់ស៊ីជម្រៅនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នោះគឺ **"កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ"** ដែលជាបរិស្ថានគ្របដណ្ដប់មួយយ៉ាងសំខាន់ ក្នុងចំណោមបរិស្ថានគ្របដណ្ដប់មានលក្ខណៈស៊ីចង្វាក់ប្រទាក់ក្រឡាគ្នា និងគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់នានារបស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យ។ ជាលទ្ធផល, ការដាក់ចេញនូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ដែលត្រូវបានយកមកអនុវត្តប្រកបដោយការទទួលខុសត្រូវខ្ពស់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ, បានផ្ដល់ផ្លែផ្កាជាវិជ្ជមានគួរជាទីលើកទឹកចិត្ត និងមានប្រសិទ្ធភាពក្នុងការកៀរគរចំណូល និងការវិភាជធនធានសាធារណៈឱ្យចំទិសដៅ សម្រាប់បម្រើឱ្យឧត្តមប្រយោជន៍របស់ប្រទេស និងប្រជាពលរដ្ឋកម្ពុជា ជាពិសេសការធានាបាននូវចីរភាពនៃកំណើនសេដ្ឋកិច្ចកម្ពុជារយៈពេលវែង។

កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ កន្លងទៅនេះ គណៈរដ្ឋមន្ត្រីបានអនុម័ត **"យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥"** ក្នុងគោលដៅកែប្រែជាជំហានៗនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ជាពិសេសឈានឆ្ពោះទៅអនុវត្តថវិកាសមិទ្ធកម្មដែលជាយុទ្ធសាស្ត្រនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនិងគណនេយ្យភាពសមិទ្ធកម្មនៅឆ្នាំ២០២៥។ ដើម្បីរួមចំណែកសម្រេចឱ្យបានតាមគោលដៅនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥នេះ ចាំបាច់ត្រូវមាន **"យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥"** ដែលមានគោលដៅឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងឡាយ

ដែលតម្រូវឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធរួមគ្នាដោះស្រាយ ក្នុងគោលដៅប្រែក្លាយប្រព័ន្ធលទ្ធកម្មសាធារណៈរបស់កម្ពុជា ឱ្យទៅជាប្រព័ន្ធមួយកាន់តែមានភាពជឿទុកចិត្ត ប្រសិទ្ធភាព ការប្រកួតប្រជែង និងការសន្សំសំចៃ ព្រមទាំងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។

យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩ -២០២៥ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត, ការវិភាគលើចំណុចខ្លាំងនិងចំណុចខ្សោយ កាលានុវត្តភាព ការគំរាមកំហែង បញ្ហាប្រឈមនានាដែលមាននៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈកម្ពុជានាពេលបច្ចុប្បន្ន, និងការដកស្រង់បទពិសោធន៍ដែលកម្ពុជាបានឆ្លងកាត់ក្នុងរយៈពេលជាង២០ឆ្នាំកន្លងទៅនេះ ក្នុងកិច្ចខិតខំប្រឹងប្រែងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ព្រមទាំងការសិក្សារៀនសូត្រនិងដកស្រង់បទពិសោធន៍ជាអន្តរជាតិពីបណ្ដាប្រទេសនានា សម្រាប់ធ្វើជាមូលដ្ឋានតម្រង់ទិសក្នុងការរៀបចំឯកសារយុទ្ធសាស្ត្រនេះឱ្យមានភាពប្រាកដនិយម ស៊ីចង្វាក់ប្រទាក់ក្រឡា និងកាន់តែមានភាពគ្រប់ជ្រុងជ្រោយ មានសង្គតិភាពជាមួយនឹងគោលនយោបាយ និងឯកសារយុទ្ធសាស្ត្រពាក់ព័ន្ធដ៏ទៃទៀតរបស់រាជរដ្ឋាភិបាល។

ខ្ញុំសូមវាយតម្លៃខ្ពស់ និងសូមថ្លែងអំណរគុណចំពោះ សមាជិក សមាជិកានៃរាជរដ្ឋាភិបាល និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់ដែលបានគាំទ្រយ៉ាងពេញទំហឹង និងបានរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាល ពិសេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលកន្លងមកប្រកបដោយសុច្ឆន្ទៈក្នុងភាពជាម្ចាស់ ការទទួលខុសត្រូវ និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាធ្វើឱ្យកម្មវិធីកែទម្រង់នេះសម្រេចបានជោគជ័យគួរឱ្យកត់សម្គាល់។ ជាមួយគ្នានេះ ក្នុងនាមប្រមុខរាជរដ្ឋាភិបាល ខ្ញុំសូមឱ្យសមាជិក សមាជិកានៃរាជរដ្ឋាភិបាល និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ គ្រប់ក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល យកចិត្តទុកដាក់ក្ដាប់ឱ្យជាប់នូវកាលានុវត្តភាពដ៏កម្រនេះ ដោយធានាទាំងស្រុងនូវភាពជាម្ចាស់ ក្នុងការបន្តកិច្ចសហការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់ចូលរួមអនុវត្តយុទ្ធសាស្ត្រកែទម្រង់ដែលរាជរដ្ឋាភិបាលទើបតែនឹងអនុម័ត ក្នុងនោះ **“យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥”** នេះ ឱ្យកាន់តែសកម្មនិងបុរេសកម្មថែមទៀត ដើម្បីសម្រេចចក្ខុវិស័យ ក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និងជាប្រជាជាតិមួយដែលរស់នៅស្មើមុខក្នុងកិច្ចការតំបន់និងពិភពលោក ព្រមទាំងកសាងសង្គមមួយប្រកបដោយភាពសុខដុមរមនាទាំងក្នុងសង្គមជាតិ និងក្រុមគ្រួសារ។

ថ្ងៃព្រហ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤ គឺមានគោលបំណងកែប្រែជាជំហានៗនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្របទៅនឹងឧត្តមានុវត្តន៍អន្តរជាតិ។ បច្ចុប្បន្ន ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបាននិងកំពុងអនុវត្តជំហានទី៣ គឺ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** " ក៏កំពុងមានវឌ្ឍនភាពល្អ ដោយនឹងគ្រោងបញ្ចប់នៅឆ្នាំ២០២០ មុននឹងឈានទៅជំហានទី៤ គឺ "**គណនេយ្យភាពសមិទ្ធកម្ម**" ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥។ ស្ថិតក្នុងទិសដៅនេះ ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨។ គោលបំណងនៃយុទ្ធសាស្ត្រនេះ គឺប្រែក្លាយជាបណ្តើរៗនូវប្រព័ន្ធថវិកាកម្ពុជាឱ្យក្លាយជាប្រព័ន្ធមួយដែលមានប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។ ការកែទម្រង់ប្រព័ន្ធថវិកា គឺមិនគ្រាន់តែជាការផ្លាស់ប្តូររបៀបរបបនៃការគ្រប់គ្រងថវិកាប៉ុណ្ណោះទេ ប៉ុន្តែការងារនេះគឺជាអភិក្រមដ៏សំខាន់បំផុតមួយនៃការកែទម្រង់អភិបាលកិច្ច ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងគណនេយ្យភាពនៃការដឹកនាំរបស់រាជរដ្ឋាភិបាលទៀតផង។ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានេះក៏បានចង្អុលឱ្យមានការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥ ដោយសារវិស័យលទ្ធកម្មសាធារណៈ គឺជាផ្នែកមួយដ៏សំខាន់នៃការគ្រប់គ្រងចំណាយសាធារណៈ។ កន្លងមក ប្រព័ន្ធលទ្ធកម្មសាធារណៈនៅកម្ពុជា ត្រូវបានពង្រឹងនិងកែលម្អជាបណ្តើរៗក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងគោលបំណង ដើម្បីពន្លឿននិងសម្រួលនីតិវិធីលទ្ធកម្មសាធារណៈឱ្យមានសង្គតិភាពជាមួយទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ គឺចាំបាច់ត្រូវធ្វើការសិក្សាលើទិដ្ឋភាពបទដ្ឋានគតិយុត្តពាក់ព័ន្ធ សិក្សាលើបញ្ហាប្រឈមក្នុងការអនុវត្តកន្លងមក និងដកស្រង់បទពិសោធន៍ដែលបានមកពីអន្តរជាតិ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ធ្វើការកែទម្រង់បន្ថែមទៀតក្នុងគោលដៅឆ្ពោះទៅកែលម្អប្រព័ន្ធលទ្ធកម្មសាធារណៈឱ្យកាន់តែមានភាពជឿទុកចិត្ត ប្រសិទ្ធភាព ការប្រកួតប្រជែង និងការសន្សំសំចៃ ព្រមទាំងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។ ក្នុងន័យនេះ ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំឡើងដើម្បីកំណត់ទិសដៅយុទ្ធសាស្ត្រ និងផែនទីចង្អុលផ្លូវសម្រាប់ធ្វើការកែទម្រង់លើសមាសធាតុគន្លឹះៗ នៃប្រព័ន្ធលទ្ធកម្មសាធារណៈដែលត្រូវអនុវត្តតាមអភិក្រមជាជំហានៗ និងជាដំណាក់កាលៗ ស្របតាមក្របខ័ណ្ឌនិងទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធាណៈឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំឡើងក្រោមការដឹកនាំកម្រិតនយោបាយដោយឯកឧត្តមបណ្ឌិត **ជុំ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកម្រិតបច្ចេកទេសដោយឯកឧត្តមបណ្ឌិត **ឈឹម សារ៉េត** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះការរៀបចំឯកសារយុទ្ធសាស្ត្រនេះក៏បានឆ្លងកាត់ការសិក្សាស្រាវជ្រាវនិងដកស្រង់បទពិសោធន៍ពីប្រទេសមួយចំនួន ជាពិសេសបទពិសោធន៍ពីប្រទេសបារាំងនិងហ្វីលីពីន បទពិសោធន៍នៃការអនុវត្តជាក់ស្តែងរបស់កម្ពុជា ការចូលរួមចែករំលែកជំនាញនិងបទពិសោធន៍ផ្ទាល់ពីអ្នកជំនាញការបរទេស និងការផ្តល់មតិយោបល់ពីដៃគូអភិវឌ្ឍន៍សំខាន់ៗ ព្រមទាំងការផ្តល់មតិយោបល់ពីក្រសួងស្ថាប័នពាក់ព័ន្ធគន្លឹះៗផងដែរ។

ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ២០១៩-២០២៥នេះ គឺជាឯកសារតម្រង់ទិសដែលកំណត់អំពីទិសដៅនិងគោលដៅច្បាស់លាស់ ប្រកបដោយភាពប្រាកដនិយម និងជាក់ស្តែងនិយម ដោយមានផែនទី

ចង្អុលផ្លូវជាត្រីវិស័យក្នុងការរៀបចំផែនការសកម្មភាពលម្អិតសម្រាប់ដំណើរការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៥។ ទន្ទឹមនឹងនេះ ឯកសារយុទ្ធសាស្ត្រនេះ ក៏បានគូសរំលេចផងដែរអំពីបញ្ហាប្រឈម និងដាក់ចេញនូវវិធានការសកម្មភាពជាក់ស្តែង ដើម្បីដោះស្រាយបញ្ហាប្រឈមនិងកែលម្អបន្ថែមទៀតលើក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត យន្តការស្ថាប័ន និងការកសាងនិងអភិវឌ្ឍន៍សមត្ថភាពតួអង្គពាក់ព័ន្ធផងដែរ។

ការកែទម្រង់នេះ ត្រូវធ្វើឡើងតាមអភិក្រមប្រុងប្រយ័ត្ន ច្បាស់លាស់ ហ្មត់ចត់ និងសកម្ម ដើម្បីធានាឱ្យការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនេះសម្រេចបានជោគជ័យ និងទាន់ពេលវេលាដែលបានគ្រោងទុក។ បន្ថែមពីលើនេះ យុទ្ធសាស្ត្រនៃការកែទម្រង់នេះ ក៏បានកំណត់គោលបំណងនិងគូសវាសផ្លូវនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈកម្ពុជាឈានឆ្ពោះទៅលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តាមរយៈការផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវកាន់តែធំ និងច្បាស់លាស់ដល់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។

ជារួម បើទោះបីជាទិសដៅនិងក្របខ័ណ្ឌពេលវេលាត្រូវបានកំណត់ច្បាស់លាស់ក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈក៏ដោយ ប៉ុន្តែនៅពេលអនុវត្តក៏អាចជួបប្រទះនូវហានិភ័យជាយថាហេតុផងដែរ។ ដូចនេះ ដើម្បីទប់ស្កាត់ និងកាត់បន្ថយនូវហានិភ័យទាំងនោះ គឺត្រូវរៀបចំវិធានការត្រៀមលក្ខណៈជាមុនផងដែរ។

ជាទីបញ្ចប់ ខ្ញុំសូមវាយតម្លៃខ្ពស់និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមបណ្ឌិត **ជូ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រធានក្រុមដឹកនាំការងាររៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ និងក្រុមការងារទាំងអស់ដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំឯកសារយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួងស្ថាប័ន និងតួអង្គពាក់ព័ន្ធទាំងអស់នឹងបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមបញ្ចូលនូវការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈផងដែរ ឱ្យឈានទៅសម្រេចបានលទ្ធផល និងទាន់តាមពេលវេលាដែលបានគ្រោងទុក។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា


| | ទំព័រទី |
|---|---|
| **បុព្វកថា** | i-ii |
| **អារម្ភកថា** | i-ii |
| **ជំពូកទី១: សេចក្តីផ្តើម** | |
| ១.១ សាវតារនៃលទ្ធកម្មសាធារណៈនៅកម្ពុជា | ១ |
| ១.២ ការកែទម្រង់លទ្ធកម្មសាធារណៈក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ១ |
| ១.៣ វិចារណកម្មនៃការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ | ២ |
| **ជំពូកទី២: ទិសដៅនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ** | ៣ |
| ២.១ ការពិនិត្យឡើងវិញលើវឌ្ឍនភាពនិងបញ្ហាប្រឈមនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ | ៣ |
| ២.២ ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង (SWOT Analysis) | ៤ |
| ២.៣ ទិសដៅនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ | ៥ |
| ២.៤ បទពិសោធន៍ពីប្រទេសហ្វីលីពីននិងបារាំង | ៦ |
| ២.៥ ការកំណត់ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ | ៧ |
| **ជំពូកទី៣: យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥** | ៨ |
| ៣.១ ការរៀបចំនិងការអនុម័តផែនការលទ្ធកម្ម | ៨ |
| ៣.២ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ | ៩ |
| ៣.២.១ ការធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈ | ៩ |
| ៣.២.២ កិច្ចដំណើរការលទ្ធកម្មសាធារណៈ | ១០ |
| ៣.២.៣ ការពង្រឹងតម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង | ១០ |
| ៣.២.៤ ការពង្រឹងការគ្រប់គ្រងការអនុវត្តកិច្ចសន្យា | ១១ |
| ៣.៣ ការត្រួតពិនិត្យនិងការវាយតម្លៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ | ១១ |
| ៣.៤ ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្តឹងតវ៉ា | ១២ |
| ៣.៥ ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ | ១៣ |
| ៣.៥.១ ការកែលម្អក្របខ័ណ្ឌគតិយុត្តនៃលទ្ធកម្មសាធារណៈ | ១៣ |
| ៣.៥.២ ការរៀបចំសៀវភៅណែនាំស្តីពីលទ្ធកម្មសាធារណៈ (Public Procurement Manual) | ១៣ |
| ៣.៥.៣ ការសិក្សាអំពីការប្រើប្រាស់លទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) | ១៤ |
| ៣.៥.៤ ការកសាងសមត្ថភាព | ១៥ |
| ៣.៦ ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ១៥ |
| ៣.៦.១ ការរៀបចំ និងការអនុម័តផែនការលទ្ធកម្ម | ១៥ |
| ៣.៦.២ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ | ១៦ |
| ៣.៦.៣ ប្រព័ន្ធរបាយការណ៍អនុវត្តកិច្ចលទ្ធកម្ម | ១៦ |

**ជំពូកទី៤: ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅនៃយុទ្ធសាស្ត្រ** ១៧
៤.១ វិសាលភាព ១៧
៤.២ ផែនទីចង្អុលផ្លូវ ១៧
៤.២.១ ការរៀបចំនិងការអនុម័តផែនការលទ្ធកម្ម ១៧
៤.២.២ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ១៨
៤.២.៣ ការត្រួតពិនិត្យនិងការវាយតម្លៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ១៨
៤.២.៤ ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្តឹងតវ៉ា ១៨
៤.២.៥ ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ១៩
៤.២.៥.១ ការកែលម្អក្របខ័ណ្ឌគតិយុត្តនៃលទ្ធកម្មសាធារណៈ ១៩
៤.២.៥.២ ការសិក្សាអំពីការប្រើប្រាស់លទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច ( e-GP) ១៩
៤.២.៥.៣ ការកសាងសមត្ថភាព ១៩
៤.៣ ការវិភាគនិងការគ្រប់គ្រងហានិភ័យ ២០
៤.៣.១ ការវិភាគហានិភ័យ ២០
៤.៣.២ ការគ្រប់គ្រងហានិភ័យ ២០
**ជំពូកទី៥: សេចក្តីសន្និដ្ឋាន** ២១
*ឧបសម្ព័ន្ធទី១ បទពិសោធន៍អំពីប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ប្រទេសហ្វីលីពីននិងបារាំង* ២២
*ឧបសម្ព័ន្ធទី២ ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅយុទ្ធសាស្ត្រឆ្នាំ២០២៥* ២៥

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១ សាវតារនៃលទ្ធកម្មសាធារណៈនៅកម្ពុជា

លទ្ធកម្មសាធារណៈមានតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកធានាតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃចំណាយសាធារណៈ។ ផ្អែកលើមូលដ្ឋានច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ១៩៩៤ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈមួយចំនួនត្រូវបានបង្កើតឡើង ដែលរួមមានអនុក្រឹត្យលេខ ៦០អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីលទ្ធកម្មសាធារណៈ និងប្រកាសលេខ ៣១៩សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៥ ស្តីពីវិធាននិងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងលទ្ធកម្មសាធារណៈ។ ចាប់តាំងពីឆ្នាំ២០០៤មក តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផ្អែកតាមបទពិសោធន៍នៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងការវិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់កម្ពុជា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈមួយចំនួនត្រូវបានបង្កើតបន្ថែមទៀតនិងកែលម្អជាបន្តបន្ទាប់សំដៅធានាឱ្យការគ្រប់គ្រងនិងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រព្រឹត្តទៅកាន់តែមានតម្លាភាព គណនេយ្យភាព ភាពប្រកួតប្រជែង និងប្រសិទ្ធភាព។ លិខិតបទដ្ឋានគតិយុត្តទាំងនោះរួមមាន អនុក្រឹត្យលេខ ១០៥អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ អនុក្រឹត្យលេខ ១៤អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីធនាគារពិភពលោកនិងធនាគារអភិវឌ្ឍន៍អាស៊ី និងប្រកាសលេខ ៣៨១សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការដាក់ឱ្យអនុវត្តសៀវភៅលទ្ធកម្មស្តីពីវិធាននិងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។ បន្ទាប់មក ច្បាប់ស្តីពីលទ្ធកម្មសាធារណៈឆ្នាំ២០១២ ព្រមទាំងអនុក្រឹត្យ ប្រកាស និងសារាចរណែនាំមួយចំនួនសម្រាប់អនុវត្តច្បាប់នេះត្រូវបានបង្កើតឡើង។ ទោះបីជាមានក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនេះក៏ដោយក៏ការគ្រប់គ្រងលទ្ធកម្មសាធារណៈនាពេលបច្ចុប្បន្ន មិនទាន់បានញែកឱ្យដាច់ពីគ្នារវាងតួនាទីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជានិយ័តករលទ្ធកម្មសាធារណៈ និងតួនាទីរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ដែលជាប្រតិបត្តិករលទ្ធកម្មសាធារណៈ។ ទន្ទឹមនេះ បទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងនិងអនុវត្តគម្រោងលទ្ធកម្មដែលប្រើប្រាស់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ នៅដាច់ដោយឡែកពីបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងនិងអនុវត្តគម្រោងលទ្ធកម្មដែលប្រើប្រាស់ថវិការដ្ឋ។ ចំណែកឯយន្តការសម្រាប់ទទួលនិងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម នៅមិនទាន់មានភាពឯករាជ្យនិងមានរបបដាក់ទោសទណ្ឌច្បាស់លាស់នៅឡើយ។

## ១.២ ការកែទម្រង់លទ្ធកម្មសាធារណៈក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការកែទម្រង់ប្រព័ន្ធថវិកា គឺជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ឈរលើមាគ៌ានៃការកែទម្រង់នេះ គោលដៅសំខាន់បំផុតមួយគឺការធ្វើឱ្យប្រព័ន្ធថវិកាកាន់តែក្លាយទៅជា "ឧបករណ៍គោលនយោបាយ" ពិតប្រាកដក្នុងការវិភាជ និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព ក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការ សំណូមពរ និងបំណងប្រាថ្នារបស់ប្រជាជន។ ក្នុងក្របខ័ណ្ឌនៃវដ្តថវិកា ការអនុវត្តថវិកាជាដំណាក់កាលដែលធនធានត្រូវបានប្រើប្រាស់ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័ន។ ប្រសិទ្ធភាពនៃការអនុវត្តចំណាយទាមទារឱ្យក្រសួង-ស្ថាប័ន និងអង្គភាពថវិកាគោរពវិន័យថវិកា និងអនុលោមតាមគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកា ដែលក្នុងនោះរួមមានទាំងនីតិវិធីអនុវត្តចំណាយឆ្លងតាមកិច្ចលទ្ធកម្មសាធារណៈផងដែរ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management Reform Programme - PFMRP) ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាដាក់ឱ្យអនុវត្តនៅខែធ្នូ ឆ្នាំ២០០៤ ដោយមានឆន្ទៈនយោបាយមុតស្រួច ឥតរាថយ និងមានគោលដៅច្បាស់លាស់គឺការផ្លាស់ប្តូរប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងវិមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការ ពោលគឺសំដៅប្រែក្លាយជាជំហានៗនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាឱ្យទៅជាប្រព័ន្ធមួយស្របតាមបទដ្ឋាននិងឧត្តមានុវត្តន៍អន្តរជាតិ។ កម្មវិធីកែទម្រង់នេះមានបួនដំណាក់កាលនិងមានគោលបំណងជាក់លាក់សម្រាប់ដំណាក់កាលនីមួយៗ ពោលគឺៈ ដំណាក់កាលទី១ គឺការបង្កើនភាពជឿទុកចិត្តបាននៃថវិកា (២០០៥-២០០៨) ដំណាក់កាលទី២ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ(២០០៩-២០១៥) ដំណាក់កាលទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ(២០១៦-២០២០) និងដំណាក់កាលទី៤ គឺការបង្កើនគណនេយ្យភាពសមិទ្ធកម្ម(២០២១-២០២៥)។

បច្ចុប្បន្ន ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានមកដល់ដំណាក់កាលទី៣ «ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ» តាមរយៈការពង្រឹងភាពជាម្ចាស់ និងការទទួលខុសត្រូវ ព្រមទាំងការផ្ទេរធនធានឱ្យកាន់តែច្រើនជូនដល់ក្រសួងស្ថាប័ន។ ក្នុងបរិបទនេះ ការគ្រប់គ្រងលទ្ធកម្មសាធារណៈជារបៀបវារៈដ៏សំខាន់ដែលត្រូវពង្រឹងឱ្យកាន់តែមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។ ជាក់ស្តែង ការកែទម្រង់លទ្ធកម្មសាធារណៈនាពេលកន្លងមក សម្រេចបានលទ្ធផលសំខាន់ៗមួយចំនួនរួមមានៈ ការបង្កើតផែនការលទ្ធកម្មប្រចាំឆ្នាំ ការបង្កើតច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តច្បាប់ ការធ្វើវិសហមជ្ឈការលទ្ធកម្ម ការបង្កើតគេហទំព័រសម្រាប់បង្ហោះព័ត៌មានលទ្ធកម្ម និងការបណ្តុះបណ្តាលដល់ក្រសួង-ស្ថាប័នជាដើម។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបាននេះ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនាពេលបច្ចុប្បន្ននេះក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវពង្រឹងនិងកែលម្អបន្ថែមទៀតក្នុងនោះរួមមានៈ ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តយន្តការស្ថាប័ននិងសមត្ថភាពគ្រប់គ្រង តម្លាភាព និងប្រសិទ្ធភាព ក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈ។ ជាមួយគ្នានេះដែរ ក្នុងរបាយការណ៍វាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយប្រើប្រាស់ "ក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ" (Public Expenditure Financial Assessment Framework-PEFA ) ក៏បានគូសបញ្ជាក់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធនឹងតម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ា។

លទ្ធផលនៃការវាយតម្លៃនេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំយុទ្ធសាស្ត្រ ផែនទីចង្អុលផ្លូវ និងផែនការសកម្មភាពលម្អិតដើម្បីកែលម្អប្រព័ន្ធលទ្ធកម្មសាធារណៈបន្ថែមទៀតឱ្យស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅដំណាក់កាលបន្ទាប់ ជាពិសេសឱ្យស្របទៅនឹងគោលដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

**១.៣ វិចារណកម្មនៃការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ**

យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ មានគោលបំណងប្រែក្លាយជាបណ្តើរៗនូវប្រព័ន្ធថវិកាកម្ពុជាឱ្យក្លាយជាប្រព័ន្ធមួយដែលមានប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានេះ ក៏បានចង្អុលបង្ហាញផងដែរអំពីទិសដៅនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ក្នុងគោលបំណងពង្រឹងយន្តការគណនេយ្យភាពតាមរយៈក្របខ័ណ្ឌនិយ័តកម្មដែលក្នុងនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើរតួនាទីជានិយ័តករនិងសវនកម្មកិច្ចលទ្ធកម្ម។ ចំណែកឯស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវមានគណនេយ្យភាពចំពោះកិច្ចលទ្ធកម្ម។ ក្នុងន័យនេះ តម្រូវឱ្យមានការផ្ទេរសិទ្ធិអំណាចនិងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មសាធារណៈជាបណ្តើរៗបន្ថែមទៀត ជូនស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ បន្ថែមពីលើនេះ ក៏តម្រូវឱ្យមានការពង្រឹងនិងកែលម្អយន្តការនៃការទទួលនិងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មឱ្យមានភាពឯករាជ្យដោយបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ និងតម្រូវឱ្យមានការធ្វើសុខដុមនីយកម្មវិធាន បទប្បញ្ញត្តិ និងនីតិវិធីនៃកិច្ចលទ្ធកម្មសាធារណៈឱ្យស្របតាមគោលការណ៍គ្រឹះនៃកិច្ចលទ្ធកម្ម និងឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីបង្កើនការប្រកួតប្រជែងប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពផងដែរ។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ គឺជាការកែទម្រង់លើសមាសធាតុគន្លឹះៗនៃប្រព័ន្ធលទ្ធកម្មសាធារណៈឱ្យស្របតាមបរិបទកម្ពុជា ព្រមទាំងបទដ្ឋាននិងឧត្តមានុវត្តន៍អន្តរជាតិ។ ក្នុងស្មារតីនេះ ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** បានសម្រេចឱ្យរៀបចំ "**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥**" ឱ្យមានសង្គតិភាពជាមួយឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

## ជំពូកទី២
## ទិសដៅនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ

ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ គឺជាការកំណត់ទិសដៅយុទ្ធសាស្ត្រ និងផែនទីចង្អុលផ្លូវ ដើម្បីកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈកម្ពុជាឱ្យស្របតាមបទដ្ឋាន និងឧត្តមានុវត្តន៍អន្តរជាតិ។ ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ នឹងត្រូវធ្វើឡើងដោយឈរលើមូលដ្ឋាននៃការពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការវិភាគលើចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព ការគំរាមកំហែង បញ្ហាប្រឈមនានានៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈកម្ពុជានាពេលបច្ចុប្បន្ន និងការដកស្រង់បទពិសោធន៍និងមេរៀនដែលទទួលបានពីការអនុវត្តជាក់ស្តែងនិងដែលបានមកពីអន្តរជាតិ ព្រមទាំងឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។ ជំពូកនេះនឹងពន្យល់ផងដែរពីសមាសធាតុគន្លឹះៗនៃទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈដែលត្រូវអនុវត្តជាជំហានៗចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៥។

### ២.១ ការពិនិត្យឡើងវិញលើវឌ្ឍនភាពនិងបញ្ហាប្រឈមនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ

ផ្អែកតាមលទ្ធផលវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយប្រើប្រាស់ “ក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA Assessment Framework) ” នៅឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទីប្រឹក្សាទទួលបន្ទុកហិរញ្ញវត្ថុសាធារណៈប្រចាំស្ថាប័នហិរញ្ញវត្ថុអន្តរជាតិបានបង្ហាញថា ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទទួលបានលទ្ធផលល្អប្រសើរ ដែលក្នុងនោះការកែទម្រង់លទ្ធកម្មសាធារណៈបានរួមចំណែកយ៉ាងសំខាន់ក្នុងការគ្រប់គ្រងលើការអនុវត្តចំណាយសាធារណៈកាន់តែមានប្រសិទ្ធភាព។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងលើការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈដោយផ្តោតសំខាន់លើបញ្ហាពាក់ព័ន្ធនឹងតម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ា។ ជារួម លទ្ធផលនៃការវាយតម្លៃនេះបង្ហាញថាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់បើប្រៀបធៀបទៅនឹងការវាយតម្លៃលើកមុន ពិសេសមានវឌ្ឍនភាពលើការបើកចំហនិងសិទ្ធិទទួលបានព័ត៌មានលទ្ធកម្ម។ ទន្ទឹមនឹងវឌ្ឍនភាពនេះ ក៏នៅមានបញ្ហាប្រឈមផងដែរពាក់ព័ន្ធនឹងការអនុវត្តវិធីសាស្ត្រលទ្ធកម្ម និងយន្តការដោះស្រាយបណ្តឹងតវ៉ាដែលត្រូវកែលម្អ។

លើសពីនេះទៀត យោងតាមលទ្ធផលនៃការវាយតម្លៃហានិភ័យអភិបាលកិច្ចនិងផែនការគ្រប់គ្រង (Country Governance Risk Assessment and Management Plan) ឆ្នាំ២០១៥ របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) លើប្រព័ន្ធលទ្ធកម្មសាធារណៈដោយប្រើប្រាស់សូចនាកររបស់អង្គការអភិវឌ្ឍន៍និងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) ដែលផ្អែកលើសសរស្តម្ភសំខាន់ៗចំនួនបួនគឺ៖ (១). ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត (Legislation and Regulatory Framework), (២). សមត្ថភាពគ្រប់គ្រងនិងក្របខ័ណ្ឌស្ថាប័ន (Institutional Framework and Management Capacity), (៣). កិច្ចដំណើរការលទ្ធកម្មនិងទីផ្សារ (Procurement Operation and Market Practice) និង (៤). តម្លាភាពនិងសុចរិតភាពក្នុងប្រព័ន្ធលទ្ធកម្ម (Integrity and Transparency in Procurement System) ក៏បានបង្ហាញថា ការកែទម្រង់លទ្ធកម្មសាធារណៈមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងនោះការកែទម្រង់ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តមានវឌ្ឍនភាពល្អប្រសើរ បើធៀបទៅនឹងការកែទម្រង់លើផ្នែក៣ផ្សេងទៀតរួមមាន៖ ការកសាងសមត្ថភាពគ្រប់គ្រងនិងក្របខ័ណ្ឌស្ថាប័ន កិច្ចប្រតិបត្តិការលទ្ធកម្មនិងទីផ្សារ និងតម្លាភាពនិងសុចរិតភាព

ក្នុងប្រព័ន្ធលទ្ធកម្ម។ ទន្ទឹមនឹងវឌ្ឍនភាពនេះ ការវាយតម្លៃនេះក៏បានគូសបញ្ជាក់ឱ្យឃើញនូវបញ្ហាប្រឈមមួយចំនួនដែលត្រូវកែលម្អ រួមមាន÷ (១).ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈនៅមិនទាន់មានការធ្វើសុខដុមនីយកម្ម ដោយចងក្រងជាឯកសារណែនាំលទ្ធកម្មរួមនៅឡើយ (២).សិទ្ធិក្នុងការទទួលបានព័ត៌មានលទ្ធកម្មសាធារណៈមិនទាន់ទូលំទូលាយ (៣).យន្តការដោះស្រាយបណ្តឹងតវ៉ាមិនទាន់ឯករាជ្យ (៤).តម្លាភាព និងប្រសិទ្ធភាពក្នុងការអនុវត្តលទ្ធកម្មសាធារណៈនៅមានកម្រិត និង (៥).ការកសាងសមត្ថភាពធនធានមនុស្សក៏នៅមានកម្រិតផងដែរ។

## ២.២ ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង (SWOT Analysis)

ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែងនៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈកម្ពុជានាពេលបច្ចុប្បន្ន ជាសមាសធាតុដ៏សំខាន់មិនអាចមើលរំលងដែលត្រូវយកមកវិភាគសម្រាប់ជាធាតុចូលក្នុងការរៀបចំឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥។

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| - មានច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់គ្រប់គ្រងនិងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ<br>- មានរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ<br>- មានការបណ្តុះបណ្តាលនិងវិក្រឹត្យការជំនាញលទ្ធកម្មសាធារណៈដល់មន្ត្រីលទ្ធកម្មជាបន្តបន្ទាប់រៀងរាល់ឆ្នាំ<br>- មន្ត្រីទទួលបន្ទុកលទ្ធកម្មភាគច្រើនមានសមត្ថភាព និងឆន្ទៈ ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ<br>- សវនកម្មកិច្ចលទ្ធកម្មត្រូវបានអនុវត្តជាទៀងទាត់<br>- ឯកសារនិងព័ត៌មានលទ្ធកម្មត្រូវបានផ្សព្វផ្សាយក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។ | - មិនទាន់ញែកដាច់ពីគ្នារវាងតួនាទីរបស់និយ័តករនិងប្រតិបត្តិករលទ្ធកម្មសាធារណៈ<br>- វិធាន បទប្បញ្ញត្តិ និងនីតិវិធីលទ្ធកម្មសម្រាប់គ្រប់គ្រងនិងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ លើកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិការដ្ឋនៅដាច់ដោយឡែកពីវិធាន បទប្បញ្ញត្តិ និងនីតិវិធីលទ្ធកម្មសម្រាប់កិច្ចលទ្ធកម្ម ដែលប្រើប្រាស់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍<br>- ការដាក់ទោសទណ្ឌដល់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ដែលបំពានវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្មមិនទាន់ចាត់វិធានការជាក់ស្តែងប្រកបដោយប្រសិទ្ធភាព<br>- ការផ្លាស់ប្តូរមន្ត្រីទទួលបន្ទុកលទ្ធកម្មញឹកញាប់នៅតាមស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់<br>- មិនទាន់មានជំនឿទុកចិត្តពេញលេញពីសាធារណជនលើប្រព័ន្ធលទ្ធកម្មសាធារណៈ<br>- អ្នកចូលរួមក្នុងការដេញថ្លៃប្រកួតប្រជែងនៅមានកម្រិត<br>- មិនទាន់មានយន្តការតាមដាន និងវាយតម្លៃលើវិជ្ជាជីវៈមន្ត្រីទទួលបន្ទុកលទ្ធកម្ម<br>- ប្រព័ន្ធព័ត៌មានវិទ្យាមិនទាន់អាចសម្រួលដល់ការគ្រប់គ្រងលទ្ធកម្មសាធារណៈបានពេញលេញ។ |

| កាលានុវត្តភាព | ការគំរាមកំហែង |
|---|---|
| - រាជរដ្ឋាភិបាលមានឆន្ទៈនយោបាយខ្ពស់ក្នុងការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ<br>- ច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលកំពុងអនុវត្តអាចយកជាមូលដ្ឋានសម្រាប់ធ្វើវិសោធនកម្ម<br>- មន្ត្រីលទ្ធកម្មមានឆន្ទៈខ្ពស់ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលនិងវិក្រឹត្យការជំនាញលទ្ធកម្មសាធារណៈ<br>- ដៃគូអភិវឌ្ឍន៍មួយចំនួនបានផ្តល់និងមានបំណងផ្តល់ជំនួយបច្ចេកទេសសម្រាប់កែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនិងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីលទ្ធកម្ម<br>- ភាពជឿនលឿន និងការពង្រីកការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេត<br>- វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមជ្ឈមណ្ឌលប្រមូលផ្តុំសម្រាប់បម្រើឱ្យការងារបណ្តុះបណ្តាល។ | - ការជ្រៀតជ្រែក ឬឥទ្ធិពលណាមួយក្នុងកិច្ចដំណើរការលទ្ធកម្មសាធារណៈ<br>- អភិបាលកិច្ចល្អនៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈមិនទាន់ត្រូវបានពង្រឹងបន្ថែម<br>- ការយល់ដឹងរបស់អ្នកដេញថ្លៃពីប្រព័ន្ធលទ្ធកម្មសាធារណៈនៅមានកម្រិត<br>- ការពន្យារពេល ឬមិនដំណើរការនៃកម្មវិធីកែទម្រង់ដទៃទៀត ដែលអាចប៉ះពាល់ដល់ល្បឿន និងប្រសិទ្ធភាពនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ<br>- ការបំបែកគម្រោងលទ្ធកម្មទៅជាគម្រោងតូចៗ ដើម្បីបញ្ចៀសការដេញថ្លៃប្រកួតប្រជែងសាធារណៈ ឬតម្រូវតាមសិទ្ធិសម្រេចលទ្ធកម្ម។ |

## ២.៣ និសដៅនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥

ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងដំណាក់កាលបន្ទាប់ត្រូវបានគណៈរដ្ឋមន្ត្រីអនុម័តកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ បានកំណត់គោលដៅជាសារវន្ត ដើម្បីឈានឆ្ពោះទៅអនុវត្តថវិកាសមិទ្ធកម្ម ស្របតាមទិសដៅជាយុទ្ធសាស្ត្រនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនិងគណនេយ្យភាពសមិទ្ធកម្មឆ្នាំ២០២៥។ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានេះ បានកំណត់គោលបំណង និងគូសវាសផ្លូវនៃការកែទម្រង់ប្រព័ន្ធថវិការបស់កម្ពុជាឈានឆ្ពោះទៅលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា តាមរយៈការប្រើប្រាស់សូចនាករសមិទ្ធកម្មនិងប្រសិទ្ធភាពនៃការអនុវត្តថវិកាតាមរយៈការកាត់បន្ថយនីតិវិធីចំណាយ និងការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវកាន់តែធំ និងច្បាស់លាស់ដល់អង្គភាពប្រតិបត្តិផ្ទាល់។

ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានេះ ក៏បានតម្រង់ទិសសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល និងបានតម្រូវឱ្យរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈដោយឡែក ក្នុងគោលបំណងពង្រឹងយន្តការគណនេយ្យភាព តាមរយៈក្របខ័ណ្ឌនិយ័តកម្ម ដែលក្នុងនោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានតួនាទីជានិយ័តករ ចំណែកស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវទទួលខុសត្រូវនិងមានគណនេយ្យភាពចំពោះការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។ ក្នុងន័យនេះ ការធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈនឹងត្រូវអនុវត្តជាបណ្តើរៗនិងពេញលេញនៅឆ្នាំ២០២៥ ហើយសមាសធាតុគន្លឹះៗមួយចំនួននៃដំណើរការលទ្ធកម្មសាធារណៈចាប់ពីការរៀបចំផែនការលទ្ធកម្មរហូតដល់ការគ្រប់គ្រងកិច្ចសន្យាលទ្ធកម្មនឹងត្រូវធ្វើការកែទម្រង់។ ទន្ទឹមនេះ សមាសធាតុគន្លឹះសំខាន់ៗដទៃទៀតដែលជារចនាសម្ព័ន្ធទ្រទ្រង់ ក៏ជារបៀបវារៈនៃការកែទម្រង់ផងដែរ។ សមាសធាតុគន្លឹះៗទាំងនោះរួមមាន÷ ការកែលម្អក្របខ័ណ្ឌគតិយុត្តនៃលទ្ធកម្មសាធារណៈ ការធ្វើសុខដុមនីយកម្មវិធាន បទប្បញ្ញត្តិ និងនីតិវិធីនៃកិច្ចលទ្ធកម្មសាធារណៈឱ្យស្របតាមគោលការណ៍គ្រឹះនៃកិច្ចលទ្ធកម្មនិងឧត្តមានុវត្តន៍អន្តរជាតិ និងចងក្រងជាឯកសារណែនាំលទ្ធកម្មរួមមួយ ការសិក្សាអំពីការប្រើប្រាស់លទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-Government Procurement) ការកសាងសមត្ថភាពតួអង្គពាក់ព័ន្ធ និងការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្តឹងតវ៉ាដោយបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ។

## ២.៤ បទពិសោធន៍ពីប្រទេសហ្វីលីពីននិងបារាំង

បទពិសោធន៍ពីទស្សនកិច្ចសិក្សាលើប្រព័ន្ធលទ្ធកម្មសាធារណៈនៅប្រទេសហ្វីលីពីននិងបារាំង បានបង្ហាញឱ្យឃើញថា ការធ្វើការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ប្រទេសទាំងពីរនេះមានលក្ខណៈស្រដៀងគ្នាមួយចំនួនទៅនឹងការកែទម្រង់លទ្ធកម្មសាធារណៈរបស់កម្ពុជាបច្ចុប្បន្ន។ ប្រទេសទាំងពីរនេះបានកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈដោយផ្អែកលើគោលការណ៍អភិបាលកិច្ចល្អក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈដែលក្នុងនោះផ្ដោតលើបញ្ហាតម្លាភាព គណនេយ្យភាព ការប្រកួតប្រជែង និងប្រសិទ្ធភាព ជាមួយនឹងការកំណត់គោលនយោបាយប្រព័ន្ធលទ្ធកម្មសាធារណៈតែមួយសម្រាប់ប្រទេស ក្នុងគោលដៅឆ្ពោះទៅការអនុវត្តលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP)។

ក្នុងទិសដៅនេះ ប្រទេសហ្វីលីពីនបានធ្វើការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈដោយការពង្រឹងយន្តការគណនេយ្យភាព តាមរយៈក្របខ័ណ្ឌនិយ័តកម្ម ដែលក្នុងនោះច្បាប់លទ្ធកម្មសាធារណៈឆ្នាំ២០០៣ ត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ២០១៧ ដើម្បីកែលម្អសមាសធាតុគន្លឹះៗមួយចំនួនដែលក្នុងនោះមានការបែងចែកសិទ្ធិអំណាចនិងការទទួលខុសត្រូវដាច់ពីគ្នារវាងស្ថាប័នគ្រប់គ្រង (ជានិយ័តករ) និងស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ (ប្រតិបត្តិករ)។

ចំពោះប្រទេសបារាំងវិញបានធ្វើការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈដោយផ្អែកលើគោលការណ៍គ្រឹះស្ដីពីតម្លាភាព និងអភិបាលកិច្ចល្អក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈតាមរយៈការកែលម្អក្របខ័ណ្ឌគតិយុត្តរបស់ខ្លួន ដើម្បីឱ្យមានសង្គតិភាពជាមួយប្រទេសអភិវឌ្ឍន៍និងតម្រូវតាមលក្ខខណ្ឌរបស់សហគមន៍អឺរ៉ុប។ ក្នុងន័យនេះ ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ប្រទេសបារាំងបច្ចុប្បន្នបានឈានដល់ការអនុវត្តលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) ទាំងស្រុងតែម្តង។

ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ប្រទេសហ្វីលីពីននិងបារាំង គឺមានការបែងចែកដាច់ពីគ្នារវាងស្ថាប័នគ្រប់គ្រង (និយ័តករ) និងស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ (ប្រតិបត្តិករ)។ នៅប្រទេសហ្វីលីពីន លទ្ធកម្មសាធារណៈត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាគោលនយោបាយលទ្ធកម្មរដ្ឋាភិបាល (Government Procurement Policy Board - GPPB) ដែលដើរតួនាទីជានិយ័តករ ហើយក្រុមប្រឹក្សានេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងថវិកានិងគ្រប់គ្រង។ ក្រុមប្រឹក្សានេះមានតួនាទីភារកិច្ចរៀបចំគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តស្ដីពីលទ្ធកម្មសាធារណៈ ផ្តល់សេវាគាំទ្រផ្នែកបច្ចេកទេសនិងកសាងសមត្ថភាពធនធានមនុស្ស ព្រមទាំងមានភារកិច្ចត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកិច្ចលទ្ធកម្មរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ ក្រៅពីក្រុមប្រឹក្សាគោលនយោបាយលទ្ធកម្មរដ្ឋាភិបាលនេះក៏នៅមានស្ថាប័នមួយទៀតគឺស្ថាប័នផ្តល់សេវាលទ្ធកម្ម (Procurement Services) ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ស្ថាប័ននេះគ្រប់គ្រងដោយប្រធានក្រុមប្រឹក្សាភិបាលដែលចាត់តាំងដោយក្រសួងថវិកានិងគ្រប់គ្រងនិងមានសមាជិកមកពីក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួន។ ស្ថាប័ននេះមានតួនាទីភារកិច្ចទទួលបន្ទុកផ្តល់សេវាដេញថ្លៃទំនិញទូទៅ (Common Goods) ជំនួសឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ ទន្ទឹមនេះ ស្ថាប័នផ្តល់សេវាលទ្ធកម្មនេះក៏អាចផ្តល់សេវាលទ្ធកម្មដេញថ្លៃទំនិញមិនទូទៅ (Non-Common Goods) និងសំណង់ (Civil Works) តាមសំណើរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ក្នុងករណីមានសំណើពីស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ដោយយកកម្រៃសេវាកម្រិតអតិបរមា ៤% នៃតម្លៃកិច្ចសន្យា។

ចំពោះស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ដំបូងត្រូវរៀបចំនិងអនុម័តផែនការលទ្ធកម្មដោយខ្លួនឯង រួចត្រូវចម្លងជូនទៅក្រុមប្រឹក្សាគោលនយោបាយលទ្ធកម្មរដ្ឋាភិបាល ដើម្បីជាមូលដ្ឋានសម្រាប់ឱ្យក្រុមប្រឹក្សានេះតាមដានការអនុវត្តកិច្ចលទ្ធកម្ម។ ផែនការលទ្ធកម្មប្រចាំឆ្នាំនេះក៏ត្រូវចម្លងជូនស្ថាប័នផ្តល់សេវាលទ្ធកម្មផងដែរ សម្រាប់ឱ្យស្ថាប័ននេះចាត់ចែងដេញថ្លៃលើមុខសញ្ញាលទ្ធកម្មទំនិញទូទៅ។ ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវមានកាតព្វកិច្ចធ្វើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មជូនក្រុមប្រឹក្សាភិបាលគោលនយោបាយលទ្ធកម្មរដ្ឋាភិបាល សម្រាប់ជាមូលដ្ឋានត្រួតពិនិត្យនិងធ្វើសវនកម្មកិច្ចលទ្ធកម្ម។

ការប្តឹងនិងការដោះស្រាយបណ្តឹងលទ្ធកម្មនៅហ្វីលីពីនគឺមានលក្ខណៈស្រដៀងគ្នានឹងប្រទេសកម្ពុជាដែរ។ អ្នកប្តឹងត្រូវប្តឹងទៅគណៈកម្មាធិការវាយតម្លៃសំណើដេញថ្លៃ។ ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការនេះ អ្នកប្តឹងអាចប្តឹងទៅប្រធានស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ហើយចុងក្រោយមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច។ អ្នកប្តឹងត្រូវបង់ថ្លៃសេវាលើរាល់ពាក្យបណ្តឹងតវ៉ាតាមច្បាប់កំណត់។

ចំពោះនៅប្រទេសបារាំងវិញ ការគ្រប់គ្រងលទ្ធកម្មសាធារណៈត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលលទ្ធកម្មរដ្ឋដែលមានតួនាទីជានិយ័តករ ហើយក្រុមប្រឹក្សាភិបាលនេះស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រៅពីក្រុមប្រឹក្សាភិបាលនេះ ក៏មានស្ថាប័នមួយទៀត គឺសហព័ន្ធប្រមូលផ្តុំទិញសាធារណៈ (Union des Groupement Acharts Public-UGAP)ដែលជាស្ថាប័នស្វយ័ត ហើយស្ថាប័ននេះមានតួនាទីភារកិច្ចធ្វើកិច្ចលទ្ធកម្មទំនិញ សេវាកម្ម និងសេវាទីប្រឹក្សា (លើកលែងតែលទ្ធកម្មសំណង់) តាមរយៈការដេញថ្លៃតាមប្រព័ន្ធអេឡិចត្រូនិច (e-GP)ជំនួសឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ទាំងអស់ ដោយយកកម្រៃសេវាកម្រិតអតិបរមា ៤%នៃតម្លៃកិច្ចសន្យាដូចនៅប្រទេសហ្វីលីពីនដែរ។ យន្តការប្តឹងតវ៉ានៅប្រទេសបារាំងវិញ គឺតម្រូវឱ្យអ្នកប្តឹងរៀបចំបណ្តឹងជាលាយលក្ខណ៍អក្សរប្តឹងទៅតុលាការគណនេយ្យតែម្តង។

សេចក្តីលម្អិតនៃបទពិសោធន៍ ដែលបានសិក្សាពីប្រទេសហ្វីលីពីននិងបារាំងមានអធិប្បាយលម្អិតនៅក្នុងឧបសម្ព័ន្ធ១នៃឯកសារយុទ្ធសាស្ត្រនេះ។

ជារួម តាមបទពិសោធន៍របស់ប្រទេសហ្វីលីពីន និងបារាំងខាងលើ ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនៅប្រទេសហ្វីលីពីនបានផ្តល់នូវមេរៀនដ៏សំខាន់ក្នុងការតម្រង់ទិសបន្ថែមសម្រាប់ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនៅកម្ពុជា។

## ២.៥ ការកំណត់ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ

ផ្អែកតាមទិសដៅនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈដែលបានកំណត់នៅក្នុងឯកសារ «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥» បទពិសោធន៍ដែលទទួលបានពីការអនុវត្តជាក់ស្តែង និងពីអន្តរជាតិ ជាពិសេសពីប្រទេសហ្វីលីពីននិងប្រទេសបារាំង លទ្ធផលនៃការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយប្រើប្រាស់ «ក្របខ័ណ្ឌវាយតម្លៃសាធារណៈនិងគណនេយ្យហិរញ្ញវត្ថុ (PEFA Assessment Framework)»ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លទ្ធផលនៃការវាយតម្លៃហានិភ័យអភិបាលកិច្ចនិងផែនការគ្រប់គ្រង និងការវិភាគ SWOT លើប្រព័ន្ធលទ្ធកម្មសាធារណៈកម្ពុជាបច្ចុប្បន្ន បានផ្តល់នូវក្របខ័ណ្ឌតម្រង់ទិសសម្រាប់ការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ។ សម្រាប់ក្របខ័ណ្ឌពេលវេលាវិញ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនឹងដើរតាមអភិក្រមនៃការកែទម្រង់ប្រព័ន្ធថវិកា ដោយសម្រេចជ្រើសរើសយក «**ថវិកាសមិទ្ធកម្ម**» ដែលកំណត់យកគោលដៅ សម្រាប់ធ្វើការផ្លាស់ប្តូរប្រព័ន្ធថវិកាជាជំហានៗរហូតដល់ឆ្នាំ២០២៥។ ដូចនេះ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនឹងគ្របដណ្តប់ការងារកែទម្រង់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៥ លើសមាសធាតុគន្លឹះមួយចំនួនដែលពាក់ព័ន្ធនឹងកិច្ចដំណើរការលទ្ធកម្មសាធារណៈនិងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ដូចមានបញ្ជាក់ក្នុងចំណុច២.៣ នៃឯកសារយុទ្ធសាស្ត្រនេះ។

## ជំពូកទី៣
## យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥

គោលបំណងនៃឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ គឺដើម្បីធ្វើឱ្យប្រព័ន្ធលទ្ធកម្មសាធារណៈក្លាយជា«**ប្រព័ន្ធមួយដែលកាន់តែមានភាពជឿទុកចិត្ត ប្រសិទ្ធភាព ការប្រកួតប្រជែង និងការសន្សំសំចៃ ព្រមទាំងស្របតាមខ្នាតគុណភាពអន្តរជាតិ**»។ ដើម្បីសម្រេចគោលបំណងនេះ គឺត្រូវកំណត់វិសាលភាពនិងសមាសធាតុគន្លឹះៗនៃប្រព័ន្ធលទ្ធកម្មសាធារណៈ ដែលត្រូវអនុវត្តតាមអភិក្រមជាជំហានៗនិងជាដំណាក់កាលៗស្របតាមក្របខ័ណ្ឌនិងទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ហើយទាមទារឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធក្នុងការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវ។

ជំពូកនេះនឹងរៀបរាប់អំពីការកែទម្រង់សមាសធាតុគន្លឹះៗ ពាក់ព័ន្ធនឹងប្រព័ន្ធលទ្ធកម្មសាធារណៈនិងការកំណត់ទិសដៅឆ្នាំ២០២៥។ ដើម្បីធានាបាននូវប្រសិទ្ធភាពនិងចីរភាពនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈចាំបាច់ត្រូវធ្វើអាទិភាពនីយកម្មលើសមាសធាតុគន្លឹះៗទាំងនោះដែលពាក់ព័ន្ធនឹង÷ (១).ការរៀបចំនិងការអនុម័តផែនការលទ្ធកម្ម (២).ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ (៣).ការត្រួតពិនិត្យនិងការវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្ម (៤).ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្តឹងតវ៉ា និងបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ និង (៥).ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ដែលរួមមាន ការកែលម្អក្របខ័ណ្ឌគតិយុត្តនៃលទ្ធកម្មសាធារណៈ ការរៀបចំសៀវភៅណែនាំស្តីពីលទ្ធកម្មសាធារណៈ ការសិក្សាអំពីការប្រើប្រាស់លទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) និងការកសាងសមត្ថភាព។

### ៣.១ ការរៀបចំនិងការអនុម័តផែនការលទ្ធកម្ម

បច្ចុប្បន្ន ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវបានធ្វើឡើងដោយផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល តួលេខនៃកញ្ចប់ថវិកាប្រចាំឆ្នាំដែលបានពិភាក្សា និងឯកភាពក្នុងពេលចរចាថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតម្រូវការប្រើប្រាស់ប្រចាំឆ្នាំរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ ការរៀបចំផែនការលទ្ធកម្ម គឺអង្គភាពអ្នកប្រើប្រាស់នីមួយៗនៃស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ត្រូវរៀបចំគម្រោងតម្រូវការប្រើប្រាស់ទំនិញ សំណង់ និងសេវាកម្មប្រចាំឆ្នាំរបស់ខ្លួន រួចបញ្ជូនទៅអង្គភាពលទ្ធកម្ម/ក្រុមលទ្ធកម្មដើម្បីប្រមូលសរុបរៀបចំជាសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដាក់ជូនគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្មនៃស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ដើម្បីពិនិត្យសម្រេច រួចស្នើសុំការឯកភាពពីប្រធានស្ថាប័នរបស់ខ្លួនមុននឹងបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងអនុម័តជូនមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។ ការអនុវត្តបែបនេះ មានស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់មួយចំនួនមានភាពយឺតយ៉ាវ ក្នុងការបញ្ជូនសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើការពិនិត្យនិងអនុម័តដែលជាហេតុនាំឱ្យការអនុវត្តចំណាយដែលត្រូវអនុវត្តតាមនីតិវិធីលទ្ធកម្មមិនទាន់ពេលវេលា និងមិនទាន់មានប្រសិទ្ធភាពពេញលេញ។

ក្នុងគោលដៅពន្លឿននិងពង្រឹងប្រសិទ្ធភាពនៃការចំណាយសាធារណៈដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំដែលបច្ចុប្បន្នត្រូវបានធ្វើឡើងក្រោយកិច្ចចរចាថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងត្រូវប្តូរការរៀបចំមកធ្វើនៅមុនដំណើរការរៀបចំចរចាថវិកាប្រចាំឆ្នាំជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញ។

ក្នុងន័យនេះ ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំភ្ជាប់មកជាមួយនឹងសំណើគម្រោងថវិកាប្រចាំឆ្នាំដើម្បីជាមូលដ្ឋាននៃការចរចាថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ។ បន្ទាប់មក ផ្អែកលើលទ្ធផលនៃការពិភាក្សាចរចាថវិកាប្រចាំឆ្នាំជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គភាពលទ្ធកម្ម/ក្រុមលទ្ធកម្មនៃស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ត្រូវធ្វើការកែសម្រួលគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ ទៅជាសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាឱ្យការពិនិត្យនិងអនុម័តជូនបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។

គោលបំណងសម្រាប់ឆ្នាំ២០២៥ ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់នៅរដ្ឋបាលថ្នាក់ជាតិត្រូវភ្ជាប់គម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំមកជាមួយនឹងសំណើគម្រោងថវិកាប្រចាំឆ្នាំ។ ការពិនិត្យសម្រេចលើគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំនឹងត្រូវធ្វើឡើងនៅក្នុងក្របខ័ណ្ឌនៃការចរចាថវិកាកម្រិតថ្នាក់ដឹកនាំស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ជាមួយថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាប់ពីឆ្នាំ២០១៩ តទៅ។ រីឯ ការពិនិត្យនិងអនុម័តសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ត្រូវធ្វើឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។ ចំពោះ ការពិនិត្យនិងអនុម័តសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់មន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវធ្វើឡើងដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ចាប់ពីឆ្នាំ២០២៣តទៅ។ ផែនការលទ្ធកម្មប្រចាំឆ្នាំនេះនឹងក្លាយជាមូលដ្ឋានសំខាន់សម្រាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់និងធានានូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការរៀបចំកម្មវិធីចំណាយប្រចាំត្រីមាស/ឆមាស។

## ៣.២ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

ការកែទម្រង់លទ្ធកម្មសាធារណៈនៅកម្ពុជាមានទិសដៅអនុវត្តតាមបែបវិមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ ដោយផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវទៅឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ ជាមួយនឹងទិសដៅនេះ ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវបានតម្រូវឱ្យអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍ជំរុញការប្រកួតប្រជែង បង្កើនតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពយុត្តិធម៌ នៅក្នុងកិច្ចដំណើរការលទ្ធកម្មសាធារណៈ។ ជាមួយគ្នានេះ ការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មក៏ជារបៀបវារៈដ៏សំខាន់ ដែលត្រូវធ្វើការពិនិត្យកែលម្អនិងពង្រឹងបន្ថែមផងដែរ។

### ៣.២.១ ការធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈ

ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនាពេលបច្ចុប្បន្នបាននិងកំពុងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តាមបែបវិសហមជ្ឈការលទ្ធកម្មសាធារណៈ ដោយផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវជាបណ្តើរៗទៅឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ តាមរយៈការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្ម។ ការអនុវត្តគោលនយោបាយនេះត្រូវបានធ្វើឡើងចាប់តាំងពីឆ្នាំ២០០៥ រហូតមកដល់បច្ចុប្បន្ន តាមរយៈការដាក់ឱ្យអនុវត្តប្រកាសលេខ ០៤៥ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ ស្តីពីការអនុវត្តវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ និងប្រកាសអន្តរក្រសួងលេខ ៥៦៨សហវ.ប្រក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការប្រគល់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ជាទិសដៅ ការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចបន្ថែមទៀតនឹងត្រូវធ្វើឡើងជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០១៩ តទៅ។ ការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចនេះ ត្រូវផ្អែកលើលទ្ធផលនៃការវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្មរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងប្តូរពីអនុវត្តកិច្ចលទ្ធកម្មសាធារណៈតាមបែបវិសហមជ្ឈការទៅវិមជ្ឈការកិច្ចលទ្ធកម្មសាធារណៈដោយផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញជូនស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់នៅឆ្នាំ២០២៥ នៅពេលមានក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើរតួនាទីជានិយ័តករពេញលេញ លើកលែងតែមុខសញ្ញាលទ្ធកម្មមួយចំនួនដែលមានទំហំធំ មានចរិតជាយុទ្ធសាស្ត្រ មានលក្ខណៈបច្ចេកទេសដោយឡែកសម្រាប់ការគ្រប់គ្រង និង/ឬមានវេទយិតភាពខ្ពស់ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ស្របតាមទិសដៅនេះ យន្តការគ្រប់គ្រងការអនុវត្តថវិកាក្រោមចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយប្រមូលផ្តុំមុខងារត្រួតពិនិត្យហិរញ្ញវត្ថុនិងកិច្ចលទ្ធកម្មក្នុងតួនាទីជាអភិបាលថវិកានឹងដាក់ឱ្យទៅអមក្រសួង ស្ថាប័នជាបណ្តើរៗចាប់ពីឆ្នាំ២០២២តទៅ។ ដោយឡែកចំពោះកិច្ចលទ្ធកម្មហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ តួនាទីអនុម័តកិច្ចសន្យានឹងត្រូវបំពេញដោយអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល អនុលោមតាមនីតិវិធីបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។

### ៣.២.២ កិច្ចដំណើរការលទ្ធកម្មសាធារណៈ

បច្ចុប្បន្ន ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈបាននិងកំពុងអនុវត្តកិច្ចលទ្ធកម្មសាធារណៈតាមបែបវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈដោយផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវជាបណ្តើរៗ ទៅឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ ការអនុវត្តគោលនយោបាយនេះ គឺដើម្បីបង្កើនតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងលទ្ធកម្មសាធារណៈតាមរយៈការពង្រឹងការបែងចែកមុខងារ ភារកិច្ច និងការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់នៅកម្រិតគ្រប់គ្រងនិងកម្រិតអនុវត្ត។ ក្នុងន័យនេះ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់មានពីរកម្រិត គឺកិច្ចលទ្ធកម្មស្ថិតក្រោមសិទ្ធិសម្រេចរបស់ខ្លួនផ្ទាល់ និងកិច្ចលទ្ធកម្មលើសសិទ្ធិសម្រេចដែលត្រូវស្នើសុំការពិនិត្យសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំហានដំបូងនៃកិច្ចដំណើរលទ្ធកម្មសាធារណៈបច្ចុប្បន្ន គឺស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំដែលបង្ហាញពីចំនួនគម្រោង តម្លៃប៉ាន់ស្មានគម្រោង វិធីសាស្ត្រលទ្ធកម្ម និងដំណាក់កាលនៃកិច្ចលទ្ធកម្មរបស់គម្រោងនីមួយៗ ហើយផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ផ្អែកតាមផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានអនុម័តរួច ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវរៀបចំស្នើសុំឥណទានធានាចំណាយ។ បន្ទាប់ពីទទួលបានឥណទានធានាចំណាយ ស្ថាប័នដែលអនុវត្តលទ្ធកម្មផ្ទាល់ត្រូវអនុវត្តកិច្ចលទ្ធកម្មសាធារណៈទៅតាមវិធីសាស្ត្រ និងនីតិវិធីដែលកំណត់ដោយក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ជារួម លទ្ធផលនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈកន្លងមកបានបង្ហាញឱ្យឃើញថា ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ភាគច្រើនបាននិងកំពុងអនុវត្តកិច្ចលទ្ធកម្មសាធារណៈបានល្អ ប៉ុន្តែទន្ទឹមនេះក៏នៅមានស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់មួយចំនួននៅមានភាពខ្វះចន្លោះមិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដែលជាហេតុមិនទាន់ធានាបានពេញលេញនូវតម្លៃនៃសាច់ប្រាក់ (Value for money) នៅឡើយ។

គោលបំណងនៅឆ្នាំ២០២៥ គឺពង្រឹងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងកែលម្អនីតិវិធីវាយតម្លៃឱ្យកាន់តែច្បាស់លាស់និងមានភាពគ្រប់ជ្រុងជ្រោយ ព្រមទាំងត្រូវរៀបចំបង្កើតប្រព័ន្ធស្តង់ដារតម្លៃ សម្រាប់ធានានូវតម្លៃនៃសាច់ប្រាក់ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

### ៣.២.៣ ការពង្រឹងតម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង

តម្លាភាពតាមរយៈការផ្សព្វផ្សាយជាចំហនូវព័ត៌មានលទ្ធកម្មសាធារណៈ ជាពិសេសព័ត៌មានអំពីការដេញថ្លៃប្រកួតប្រជែងជាសាធារណៈគឺជាសមាសធាតុគន្លឹះនៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈ។ ព័ត៌មានសំខាន់ៗពាក់ព័ន្ធលទ្ធកម្មសាធារណៈនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ លើកលែងតែព័ត៌មានមួយចំនួនដែលពាក់ព័ន្ធដល់ការសម្ងាត់និងមានវេទយិតភាពខ្ពស់។ ព័ត៌មានពាក់ព័ន្ធលទ្ធកម្មត្រូវរៀបចំឡើងក្នុងទម្រង់សាមញ្ញងាយស្រួលយល់ ធ្វើបច្ចុប្បន្នភាពជាទៀងទាត់ និងអាចទទួលបានទាន់ពេលវេលា។ បន្ថែមពីលើនេះ ក៏ត្រូវបង្កភាពងាយស្រួលដល់អ្នកដេញថ្លៃក្នុងការទទួលបានសិទ្ធិចូលរួមក្នុងការដេញថ្លៃផងដែរ។

បច្ចុប្បន្ន ការផ្សព្វផ្សាយព័ត៌មានលទ្ធកម្មសំខាន់ៗមួយចំនួនត្រូវបានធ្វើឡើងនៅលើគេហទំព័រលទ្ធកម្មរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ព័ត៌មានលទ្ធកម្មសំខាន់ៗពាក់ព័ន្ធលទ្ធកម្មទាំងនោះរួមមាន÷ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ សេចក្តីជូនដំណឹងអំពីការដេញថ្លៃ សេចក្តីជូនដំណឹងអំពីការសម្រេចប្រគល់កិច្ចសន្យា ផែនការលទ្ធកម្ម និង

របាយការណ៍ត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយជាដើម។ គោលបំណងនៃការផ្សព្វផ្សាយព័ត៌មានទាំងនេះ គឺដើម្បីលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង ព្រមទាំងផ្តល់ជាមូលដ្ឋានសម្រាប់ការចូលរួមក្នុងការដេញថ្លៃ។ ផ្អែកតាមការវាយតម្លៃរបស់ដៃគូអភិវឌ្ឍន៍កន្លងមក បានបង្ហាញថាការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅមានចំណុចខ្វះចន្លោះមួយចំនួនដែលត្រូវកែលម្អ ដើម្បីពង្រឹងតម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង។ កិច្ចដំណើរការលទ្ធកម្មសាធារណៈកន្លងមក ទោះបីជាមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីព័ត៌មានស្តីពីការដេញថ្លៃប្រកួតប្រជែងជាសាធាណៈតាមរយៈសារព័ត៌មាននិងគេហទំព័រក៏ដោយ ក៏ចំនួនអ្នកចូលរួមដេញថ្លៃនៅមានកម្រិតនៅឡើយ។ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈបានចែងថា វិធីសាស្រ្តដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ជាវិធីសាស្រ្តលទ្ធកម្មដែលមានកម្រិតតម្លាភាពខ្ពស់និងដែលត្រូវជំរុញឱ្យប្រើក្នុងកិច្ចលទ្ធកម្មសាធារណៈ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងមាននិន្នាការងាកទៅរកការប្រើប្រាស់វិធីសាស្រ្តលទ្ធកម្មដោយឡែក។ បន្ថែមពីលើនេះ ក៏មានការបំបែកគម្រោងលទ្ធកម្មទៅជាគម្រោងតូចៗក្នុងគោលបំណងគេចវេះពីការដេញថ្លៃប្រកួតប្រជែង និងតម្រូវទៅតាមសិទ្ធិសម្រេចរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ផងដែរ។

គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែងក្នុងដំណើរការកិច្ចលទ្ធកម្មសាធារណៈ តាមរយៈការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ និងចាត់វិធានការជាក់លាក់និងម៉ឺងម៉ាត់ចំពោះស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ដែលបានបំពានច្បាប់ វិធាន និងបទប្បញ្ញត្តិពាក់ព័ន្ធលទ្ធកម្មសាធារណៈ។

### ៣.២.៤ ការពង្រឹងការគ្រប់គ្រងការអនុវត្តកិច្ចសន្យា

ការគ្រប់គ្រងការអនុវត្តកិច្ចសន្យា មានសារៈសំខាន់ចំពោះស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ដើម្បីធានាឱ្យរាល់កាតព្វកិច្ចនិងលក្ខខណ្ឌទាំងអស់នៃកិច្ចសន្យា ត្រូវបានអនុវត្តត្រឹមត្រូវដោយភាគីនៃកិច្ចសន្យា។ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកិច្ចសន្យា ចាំបាច់ត្រូវមានលិខិតបទដ្ឋានគតិយុត្តនិងយន្តការត្រួតពិនិត្យច្បាស់លាស់ ប្រកបដោយវិជ្ជាជីវៈ និងមានការទទួលខុសត្រូវខ្ពស់។ ទន្ទឹមនេះ ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវមានយន្តការគ្រប់គ្រង ត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកិច្ចសន្យា ព្រមទាំងគ្រប់គ្រងបញ្ហាដែលអាចកើតឡើងត្រូវបានដោះស្រាយភ្លាមៗ ឬអនុវត្តវិធានការការពារជាមុនកុំឱ្យមានបញ្ហាកើតឡើង។ ការគ្រប់គ្រងការអនុវត្តកិច្ចសន្យារបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ប្រកបដោយប្រសិទ្ធភាព គឺធានាបាននូវការអនុវត្តត្រឹមត្រូវតាមបរិមាណ គុណភាព លក្ខណៈបច្ចេកទេស គំនូសប្លង់ និងទាន់ពេលវេលាកំណត់។

គោលដៅសម្រាប់ឆ្នាំ២០២៥ គឺពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងការអនុវត្តកិច្ចសន្យាបច្ចុប្បន្ន។ បន្ថែមពីលើនេះ ក៏ត្រូវកែលម្អបន្ថែមលើលិខិតបទដ្ឋានគតិយុត្តនេះ ឱ្យកាន់តែច្បាស់លាស់ ពេញលេញ និងគ្រប់ជ្រុងជ្រោយ។

## ៣.៣ ការត្រួតពិនិត្យនិងការវាយតម្លៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

បច្ចុប្បន្នការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវបានធ្វើឡើងតាមរយៈការធ្វើសវនកម្មលើកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិការដ្ឋនិងស្ថិតក្រោមសិទ្ធិសម្រេចរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ដោយមិនបានគ្របដណ្តប់លើកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍។ ការធ្វើសវនកម្មកិច្ចលទ្ធកម្មនេះ

ទៀតសោត គឺផ្តោតជាសំខាន់តែលើអនុលោមភាពតាមក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈប៉ុណ្ណោះ ជាជាងទៅលើលទ្ធផលសម្រេចបាន។ ម្យ៉ាងវិញទៀត ការធ្វើសវនកម្មកិច្ចលទ្ធកម្មនៅមិនទាន់មានលក្ខណៈរឹងមាំនៅឡើយ ដោយសារសមត្ថភាពនិងការយល់ដឹងលើផ្នែកសវនកម្មកិច្ចលទ្ធកម្មនៅមានកម្រិត និងមិនទាន់មានវិធានការច្បាស់លាស់សម្រាប់ដាក់ទោសទណ្ឌចំពោះការបំពានច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ។

គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺត្រូវពង្រឹងការត្រួតពិនិត្យនិងការវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្មសាធារណៈទាំងលើកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិការដ្ឋនិងកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ដោយត្រូវផ្តោតទាំងលើអនុលោមភាពតាមក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងទាំងលើលទ្ធផលសម្រេចបានផងដែរ ព្រមទាំងបង្កើតឱ្យមានរបបដាក់ទោសទណ្ឌច្បាស់លាស់ចំពោះការបំពានច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងបង្កើនការយល់ដឹងនិងការកសាងសមត្ថភាពផ្នែកសវនកម្មកិច្ចលទ្ធកម្ម។

## ៣.៤ ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្តឹងតវ៉ា

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មាត្រា៦២បានចែងថា "សាមីស្ថាប័នអនុវត្តលទ្ធកម្មមានសមត្ថកិច្ចទទួលពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃ នៅគ្រប់ដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្ម។ អ្នកប្តឹងដែលមិនយល់ព្រមនឹងសេចក្តីសម្រេចរបស់សាមីស្ថាប័នអនុវត្តកិច្ចលទ្ធកម្មអាចប្តឹងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យនិងដោះស្រាយ"។ ផ្អែកតាមបញ្ញត្តិនៃច្បាប់នេះ បែបបទ នីតិវិធី និងយន្តការទទួលពាក្យបណ្តឹងនិងដោះស្រាយពាក្យបណ្តឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តតាមរយៈអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីបែបបទនិងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម។ អនុក្រឹត្យនេះ បានកំណត់អំពីសិទ្ធិក្នុងការប្តឹងតវ៉ា បែបបទនិងនីតិវិធីនៃការដាក់ពាក្យបណ្តឹងនិងដោះស្រាយពាក្យបណ្តឹងតវ៉ា ព្រមទាំងកំណត់ពីយន្តការសម្រាប់ការប្តឹង ក្នុងគោលបំណងដើម្បីធានាឱ្យការដោះស្រាយបណ្តឹងតវ៉ាត្រូវបានធ្វើឡើងប្រកបដោយសុចរិតយុត្តិធម៌ និងគ្មានការរើសអើង។ ការប្តឹងតវ៉ាអាចកើតឡើងនៅពេលអ្នកដេញថ្លៃពិនិត្យឃើញថា មានភាពមិនប្រក្រតីកើតឡើងក្នុងដំណើរការនៃកិច្ចលទ្ធកម្មសាធារណៈ ហើយការប្តឹងតវ៉ានេះត្រូវធ្វើឡើងតាមលំដាប់លំដោយ ជាដំបូងត្រូវប្តឹងទៅសាមីស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ បន្ទាប់មកអាចប្តឹងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងចុងក្រោយអាចទៅតុលាការមានសមត្ថកិច្ច។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសមត្ថកិច្ចទទួលពិនិត្យនិងដោះស្រាយពាក្យបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃ នៅពេលដែលអ្នកប្តឹងមិនពេញចិត្តនឹងដំណោះស្រាយរបស់សាមីស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ ប៉ុន្តែ ប្រសិនបើអ្នកប្តឹងតវ៉ានោះនៅតែមិនពេញចិត្តនឹងដំណោះស្រាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៀត អាចប្តឹងបន្តទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។ យន្តការដោះស្រាយពាក្យបណ្តឹងតវ៉ាបែបនេះនៅមិនទាន់ត្រូវបានចាត់ទុកថាមានលក្ខណៈឯករាជ្យនៅឡើយ។

គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺកែលម្អក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដោយបង្កើតយន្តការឯករាជ្យសម្រាប់ដោះស្រាយបណ្តឹងតវ៉ាដែលកើតចេញពីការអនុវត្តគម្រោងលទ្ធកម្មដែលប្រើប្រាស់ថវិការដ្ឋនិងថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើតឱ្យមានរបបដាក់ទោសទណ្ឌនៅពេលដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្លាយជានិយ័តករពេញលេញ។

## ៣.៥ ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់

### ៣.៥.១ ការកែលម្អក្របខ័ណ្ឌគតិយុត្តនៃលទ្ធកម្មសាធារណៈ

ផ្អែកតាមបញ្ញត្តិនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ និងមានសិទ្ធិអំណាចរៀបចំគោលនយោបាយលទ្ធកម្មសាធារណៈព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។ ក្រៅពីច្បាប់នេះមានលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតត្រូវបានបង្កើតឡើងសម្រាប់គ្រប់គ្រងនិងអនុវត្តកិច្ចលទ្ធកម្មសាធារណៈទាំងនៅរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលឃុំ សង្កាត់ ដែលត្រូវគ្រប់គ្រងនិងអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តដោយឡែក។ ប៉ុន្តែ ទោះបីជាលិខិតបទដ្ឋានគតិយុត្តទាំងនោះត្រូវបានរៀបចំឡើងក្នុងគោលដៅនិងគោលបំណងរួម ដើម្បីឆ្លើយតបបានទៅនឹងគោលការណ៍ និងវិធានដែលបានបញ្ញត្តិដោយច្បាប់នេះក៏ដោយ ក៏លិខិតបទដ្ឋានគតិយុត្តទាំងនោះត្រូវបានរៀបចំឡើងដាច់ដោយឡែកៗពីគ្នា។

ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាននាពេលកន្លងមក បានបង្ហាញឱ្យឃើញថាបទដ្ឋានគតិយុត្តទាំងនេះនៅមិនទាន់បែងចែកឱ្យដាច់ពីគ្នារវាងការគ្រប់គ្រង និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។ បន្ថែមពីលើនេះ លិខិតបទដ្ឋានគតិយុត្តទាំងនេះក៏មិនទាន់ឆ្លើយតបបានពេញលេញទៅនឹងប្រព័ន្ធលទ្ធកម្មសាធារណៈស្របតាមបទដ្ឋាននិងឧត្តមានុវត្តន៍អន្តរជាតិ ព្រមទាំងមិនទាន់ឆ្លើយតបបានគ្រប់ជ្រុងជ្រោយទៅនឹងការវិវត្តនៃប្រព័ន្ធគ្រប់គ្រងថវិកាស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥នៅឡើយ។

គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺត្រូវធ្វើវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈនិងកែលម្អលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដើម្បីពង្រឹងយន្តការគណនេយ្យភាពតាមរយៈក្របខ័ណ្ឌនិយ័តកម្ម ដែលក្នុងនោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានតួនាទីជានិយ័តករនិងសវនកម្មកិច្ចលទ្ធកម្ម ចំណែកឯស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវទទួលខុសត្រូវនិងមានគណនេយ្យភាពចំពោះកិច្ចលទ្ធកម្ម។ ក្នុងតួនាទីជានិយ័តករ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានតួនាទីភារកិច្ចសំខាន់ៗពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជាអាទិ៍÷

- រៀបចំគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់គ្រប់គ្រងលទ្ធកម្មសាធារណៈ
- បណ្តុះបណ្តាលនិងវិក្រឹត្យការជំនាញលទ្ធកម្មជូនដល់មន្ត្រីនៃស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់និងតួអង្គពាក់ព័ន្ធដទៃទៀត
- សវនកម្មកិច្ចលទ្ធកម្ម
- ដោះស្រាយបណ្តឹងតវ៉ានិងវិវាទលទ្ធកម្ម។

### ៣.៥.២ ការរៀបចំសៀវភៅណែនាំស្តីពីលទ្ធកម្មសាធារណៈ (Public Procurement Manual)

បច្ចុប្បន្ន ការគ្រប់គ្រងនិងការអនុវត្តលទ្ធកម្មសាធារណៈត្រូវបានគ្រប់គ្រងដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ច្បាប់នេះបានចែងពីគោលការណ៍ណែនាំសំខាន់ៗ ចំណែកឯនីតិវិធីលម្អិតសម្រាប់គ្រប់គ្រងនិងអនុវត្តត្រូវបានចែងក្នុងលិខិតបទដ្ឋានគតិយុត្តផ្សេងៗគ្នា។ ទោះបីជាលិខិតបទដ្ឋានគតិយុត្តទាំងនេះត្រូវបានរៀបចំឡើងក្នុងគោលដៅនិងគោលបំណងរួម ដើម្បីឆ្លើយតបបានទៅនឹងគោលការណ៍ និងវិធានដែលបានបញ្ញត្តិដោយច្បាប់ក៏ដោយ ប៉ុន្តែការរៀបចំលិខិតបទដ្ឋានគតិយុត្តទាំងនោះត្រូវបានធ្វើឡើងដាច់ដោយឡែកៗពីគ្នា មិនទាន់ចងក្រងប្រមូលផ្តុំដាក់ជាឯកសារតែមួយនៅឡើយ។ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈក៏បានបញ្ញត្តិជាធរមានអំពីការអនុវត្តគោលការណ៍និងនីតិវិធីដោយឡែកសម្រាប់អនុវត្តកិច្ចលទ្ធកម្មនៃគម្រោងដែលហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ដែលមានចែងក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។ ជាដំណោះស្រាយសម្រាប់ពេលអនាគត គឺត្រូវពិនិត្យនិងរៀបចំចងក្រងប្រមូលផ្តុំនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដាក់ក្នុងឯកសារតែមួយដើម្បីបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រងនិងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺត្រូវរៀបចំបង្កើត «សៀវភៅណែនាំស្តីពីលទ្ធកម្មសាធារណៈ (Public Procurement Manual)» ដែលរួមបញ្ចូលនូវគោលការណ៍ វិធាន និងនីតិវិធីលទ្ធកម្មសម្រាប់គ្រប់គ្រងនិងអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅទូទាំងប្រទេស។

### ៣.៥.៣ ការសិក្សាអំពីការប្រើប្រាស់លទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP)

កិច្ចដំណើរការលទ្ធកម្មសាធារណៈនាពេលបច្ចុប្បន្ន គឺធ្វើឡើងតាមលក្ខណៈសាមញ្ញដោយផ្អែកលើក្រដាសស្នាម (Traditional Paper-based Procurement) ដែលនាំឱ្យមានផលលំបាកមួយចំនួនដែលជាហេតុនាំឱ្យការគ្រប់គ្រងព័ត៌មានមិនពេញលេញ នីតិវិធីវែង និងចំណាយពេលវេលាច្រើន។ ការបន្តអនុវត្តកិច្ចលទ្ធកម្មតាមលក្ខណៈសាមញ្ញបែបនេះក៏ជាបញ្ហាក្នុងការបង្អាក់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់សម្រួលដល់ការគ្រប់គ្រងនិងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ ចាប់ពីឆ្នាំ២០១១ រហូតដល់បច្ចុប្បន្នក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំនិងដាក់ឱ្យដំណើរការគេហទំព័រលទ្ធកម្មសាធារណៈដើម្បីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងលទ្ធកម្មសំខាន់ៗ។ បន្ថែមពីលើនេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System- FMIS) បាននិងកំពុងពង្រីកវិសាលភាពរបស់ខ្លួនដល់គ្រប់ក្រសួងស្ថាប័ននៅឆ្នាំ២០២០ ដែលក្នុងនោះមុខងារលទ្ធកម្មត្រូវបានអនុវត្តត្រឹមកម្រិតមុខងារធានាចំណាយនិងការបញ្ជាទិញ។ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)នេះ គឺជាមូលដ្ឋានសម្រាប់ការបោះជំហានទៅកាន់ការរៀបចំបង្កើតលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP)។

ដើម្បីធានាឱ្យការអនុវត្តកិច្ចលទ្ធកម្មសាធារណៈអាចប្រព្រឹត្តទៅដោយរលូន និងកាន់តែមានតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ គឺត្រូវសិក្សានិងរៀបចំបង្កើតក្របខ័ណ្ឌគតិយុត្តសម្រាប់អនុវត្តលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ដែលបាននិងកំពុងអនុវត្តបច្ចុប្បន្ន។ ការអនុវត្តកិច្ចលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) នឹងផ្តល់អត្ថប្រយោជន៍ជាអាទិ៍÷

- បង្កើនតម្លាភាពក្នុងនីតិវិធីលទ្ធកម្ម និងការអនុវត្តលទ្ធកម្មសាធារណៈ
- ការធ្វើឱ្យប្រសើរឡើងនៃប្រសិទ្ធភាពនៅក្នុងដំណើរការកិច្ចលទ្ធកម្មតាមរយៈការកាត់បន្ថយរយៈពេលនៃការអនុវត្តកិច្ចលទ្ធកម្ម បង្កើនតម្លៃនៃសាច់ប្រាក់ និងការលើកកម្ពស់គណនេយ្យភាព
- លើកកម្ពស់ការរក្សាការសម្ងាត់ ភាពសុចរិតនៃប្រតិបត្តិការរវាងស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ និងអ្នកដេញថ្លៃ
- បង្កើតមូលដ្ឋានទិន្នន័យរួម និងប្រព័ន្ធអេឡិចត្រូនិចរបស់លទ្ធកម្ម ដើម្បីជួយសម្រួលដល់ការត្រួតពិនិត្យរបាយការណ៍ និងការរៀបចំផែនការលទ្ធកម្ម។

គោលបំណងសម្រាប់ឆ្នាំ២០២៥ នឹងដាក់ចូលបន្ថែមនូវមុខងារលទ្ធកម្មមួយចំនួនទៀតទៅក្នុងប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ជាបណ្តើរៗ។ ចំពោះ ការរៀបចំនិងដាក់ឱ្យអនុវត្តកិច្ចលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) នឹងត្រូវធ្វើឡើងដោយផ្អែកតាមការសិក្សាវាយតម្លៃលើប្រព័ន្ធលទ្ធកម្មនិងការវិវត្តនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ។ ទន្ទឹមនេះ ត្រូវសិក្សារៀនសូត្រនិងដកស្រង់បទពិសោធន៍ពីបណ្តាប្រទេសក្នុងតំបន់និងពិភពលោក ដែលបាននិងកំពុងអនុវត្តកិច្ចលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិចជោគជ័យ ដើម្បីប្រមូលធាតុចូលសម្រាប់រៀបចំផែនការសកម្មភាពក្នុងការរៀបចំលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP)។

### ៣.៥.៤ ការកសាងសមត្ថភាព

កន្លងមក ការបណ្តុះបណ្តាលជំនាញលទ្ធកម្មសាធារណៈមិនទាន់ត្រូវបានធ្វើឡើងជាប្រព័ន្ធនៅឡើយ ចំណែកឯការបណ្តុះបណ្តាលនោះទៀតសោត មានរយៈពេលខ្លីនិងធ្វើឡើងតាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយការសហការរវាងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនិងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងករណីខ្លះ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបានអនុវត្តវគ្គបណ្តុះបណ្តាលដោយផ្ទាល់តាមតម្រូវការជាក់ស្តែង ស្របតាមលិខិតបទដ្ឋានគតិយុត្តថ្មីៗដែលត្រូវបានដាក់ឱ្យអនុវត្តតាមរយៈការរៀបចំសិក្ខាសាលា និងការផ្សព្វផ្សាយជាដើម។ ទោះបីជាការអនុវត្តសកម្មភាពបណ្តុះបណ្តាលបែបនេះទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ក៏ដោយ ប៉ុន្តែទន្ទឹមនេះ ក៏នៅមានបញ្ហាប្រឈមនៅឡើយ ជាពិសេសក្រោយពេលអង្គភាពថវិកាត្រូវបានបង្កើតឡើងដែលតម្រូវឱ្យមានក្រុមលទ្ធកម្ម សម្រាប់ទទួលបន្ទុកក្នុងការគ្រប់គ្រងនិងអនុវត្តកិច្ចលទ្ធកម្មសាធារណៈដោយផ្ទាល់។ ក្នុងន័យនេះ ដើម្បីបន្តកសាងសមត្ថភាពមន្ត្រីលទ្ធកម្ម គឺចាំបាច់ត្រូវបង្កើតប្រព័ន្ធបណ្តុះបណ្តាលនិងវិក្រឹត្យការ ដែលមានលក្ខណៈប្រមូលផ្តុំនិងគ្រប់ជ្រុងជ្រោយ ដើម្បីធានាឱ្យការបណ្តុះបណ្តាលនិងអភិវឌ្ឍន៍សមត្ថភាពប្រកបដោយប្រសិទ្ធភាព និងគុណភាព ពោលគឺធ្វើឱ្យមន្ត្រីអនុវត្តកិច្ចលទ្ធកម្មសាធារណៈមានចំណេះដឹង ជំនាញវិជ្ជាជីវៈ និងគុណវុឌ្ឍិគ្រប់គ្រាន់ សម្រាប់ចូលរួមអនុវត្តយុទ្ធសាស្រ្តនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈសម្រេចបានជោគជ័យដោយប្រសិទ្ធភាពនិងចីរភាព ។

គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺបន្តពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្សលើមុខជំនាញលទ្ធកម្មសាធារណៈ ដែលមានលក្ខណៈប្រមូលផ្តុំជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមជ្ឈមណ្ឌលបណ្តុះបណ្តាល ដោយអនុលោមតាមស្មារតីនៃផែនការយុទ្ធសាស្រ្តស្តីពីការកសាងនិងអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨។

## ៣.៦ ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

បច្ចុប្បន្ន ការគ្រប់គ្រងនិងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិផ្អែកលើច្បាប់ស្តីពីលទ្ធកម្មសាធារណៈឆ្នាំ២០១២និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានដទៃទៀត លើកលែងតែរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវគ្រប់គ្រងនិងអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តដោយឡែក។ ការកែទម្រង់ការគ្រប់គ្រងនិងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាល ឃុំ សង្កាត់នឹងត្រូវកំណត់ក្នុងឯកសារយុទ្ធសាស្រ្តនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥។

### ៣.៦.១ ការរៀបចំនិងការអនុម័តផែនការលទ្ធកម្ម

បច្ចុប្បន្ន ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានធ្វើឡើងដោយផ្អែកលើផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល និងតួលេខកញ្ចប់ថវិកាប្រចាំឆ្នាំ។ ផែនការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានរៀបចំដោយអង្គភាពលទ្ធកម្មរាជធានី ខេត្ត រួចបញ្ជូនទៅគណៈកម្មាធិការលទ្ធកម្មរាជធានី ខេត្ត ពិនិត្យនិងសម្រេច ព្រមទាំងសុំការពិនិត្យនិងឯកភាពពីក្រុមប្រឹក្សារាជធានី ខេត្ត មុននឹងបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងអនុម័ត។ ចំណែកផែនការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ កិច្ចដំណើរការរៀបចំដូចគ្នានឹងការរៀបចំផែនការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តដែរ ប៉ុន្តែការពិនិត្យនិងអនុម័តចុងក្រោយត្រូវធ្វើឡើងដោយមន្ទីរ

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។ ចំពោះផែនការលទ្ធកម្មរបស់មន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំឡើងដោយក្រុមលទ្ធកម្ម នៃអង្គភាពថវិកា បន្ទាប់មកត្រូវបញ្ជូនទៅអង្គភាពលទ្ធកម្មនៃក្រសួង ស្ថាប័នសាមីដើម្បីបញ្ចូលជាឧបសម្ព័ន្ធនៃផែនការលទ្ធកម្មរបស់សាមីក្រសួង ស្ថាប័ន រួចបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យនិងអនុម័ត។

គោលបំណងសម្រាប់ឆ្នាំ២០២៥ ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវពិនិត្យនិងអនុម័តដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។ ផែនការលទ្ធកម្មប្រចាំឆ្នាំនេះនឹងក្លាយជាមូលដ្ឋានសំខាន់សម្រាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងធានានូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃការរៀបចំកម្មវិធីចំណាយប្រចាំត្រីមាស/ឆមាស។

### ៣.៦.២ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

បច្ចុប្បន្នការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុវត្តតាមបែបវិសហមជ្ឈការលទ្ធកម្ម។ ក្នុងន័យនេះ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានពីរកម្រិតដូចការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ជាតិដែរ គឺកិច្ចលទ្ធកម្មសាធារណៈដែលពិនិត្យសម្រេចដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផ្ទាល់ និងកិច្ចលទ្ធកម្មសាធារណៈដែលតម្រូវឱ្យស្នើសុំការពិនិត្យសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គោលបំណងសម្រាប់ឆ្នាំ២០២៥ គឺធ្វើវិមជ្ឈការលទ្ធកម្មដោយផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវទាំងស្រុងជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅពេលមានក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើរតួនាទីជានិយ័តករពេញលេញ លើកលែងតែមុខសញ្ញាលទ្ធកម្មមួយចំនួនដែលមានទំហំធំ មានចរិតជាយុទ្ធសាស្ត្រ មានលក្ខណៈបច្ចេកទេសដោយឡែកសម្រាប់ការគ្រប់គ្រង និង/ឬមានវេទយិតភាពខ្ពស់ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៣.៦.៣ ប្រព័ន្ធរបាយការណ៍អនុវត្តកិច្ចលទ្ធកម្ម

បច្ចុប្បន្ន របាយការណ៍អនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានរៀបចំនិងបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំណែកឯ របាយការណ៍អនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំនិងបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីបូកសរុប រួចបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដោយឡែក របាយការណ៍អនុវត្តកិច្ចលទ្ធកម្មរបស់មន្ទីរជំនាញរាជធានី ខេត្តត្រូវបានរៀបចំនិងបញ្ជូនទៅអង្គភាពលទ្ធកម្មរបស់សាមីក្រសួង ស្ថាប័នដើម្បីបូកសរុប រួចបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គោលបំណងសម្រាប់ឆ្នាំ២០២៥ របាយការណ៍អនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវរៀបចំតាមគំរូថ្មី និងបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបូកសរុបរួចបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី៤
# ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅយុទ្ធសាស្ត្រ

ជំពូកទី៤នេះ គូសរំលេចអំពីផែនទីចង្អុលផ្លូវក្នុងក្របខ័ណ្ឌនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈកម្ពុជា ចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៥ និងដាក់ចេញនូវសកម្មភាពកែទម្រង់តាមអភិក្រមជាក់ស្តែងផ្អែកតាមការសិក្សាវិភាគគ្រប់ជ្រុងជ្រោយ ដើម្បីដោះស្រាយបញ្ហាប្រឈមនានាក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈបច្ចុប្បន្ន សំដៅសម្រេចបាននូវគោលបំណងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈដូចបានកំណត់នៅក្នុងជំពូកទី៣។

## ៤.១ ទិសាលភាព

ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនេះ គឺគ្របដណ្តប់លើសមាសធាតុគន្លឹះៗជាយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធទៅនឹង÷ (១).ការរៀបចំនិងការអនុម័តផែនការលទ្ធកម្ម (២).ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ (៣).ការត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ (៤).ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្តឹងតវ៉ា ដោយបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ និង (៥).ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ដែលរួមមាន÷ ការកែលម្អក្របខ័ណ្ឌគតិយុត្តនៃលទ្ធកម្មសាធារណៈ ការរៀបចំសៀវភៅណែនាំស្តីពីលទ្ធកម្មសាធារណៈ ការសិក្សាអំពីការប្រើប្រាស់លទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) និងការកសាងសមត្ថភាព។

## ៤.២ ផែនទីចង្អុលផ្លូវ

### ៤.២.១ ការរៀបចំនិងការអនុម័តផែនការលទ្ធកម្ម

ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំនឹងត្រូវអនុវត្តក្រោមក្របខ័ណ្ឌគតិយុត្តរួមមួយគ្រប់ជ្រុងជ្រោយនិងច្បាស់លាស់ ដើម្បីបំពេញបន្ថែមឱ្យការអនុវត្តបច្ចុប្បន្ន ដែលផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានធ្វើឡើងដោយផ្អែកតាមប្រកាសលេខ ៨៥១សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម។ ក្នុងន័យនេះ ជំនួសឱ្យនីតិវិធីបច្ចុប្បន្នដែលផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានរៀបចំនិងសម្រេចក្រោយកិច្ចចរចាថវិកានិងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងប្រចាំឆ្នាំត្រូវបានអនុម័ត មកជាការពិនិត្យនិងសម្រេចផែនការលទ្ធកម្មប្រចាំឆ្នាំនឹងត្រូវធ្វើនៅក្នុងក្របខ័ណ្ឌនៃការចរចាថវិកាកម្រិតថ្នាក់ដឹកនាំស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចាប់ពីឆ្នាំ២០១៩តទៅ។ ដូចនេះ ការរៀបចំកែលម្អលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំនឹងត្រូវធ្វើឡើងនៅឆ្នាំ២០១៩។

ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់នៅថ្នាក់កណ្តាលត្រូវពិនិត្យនិងអនុម័ត ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះ ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ដែលជារដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវពិនិត្យនិងអនុម័តជាផ្លូវការដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចាប់ពីឆ្នាំ២០២៣។

### ៤.២.២ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

ក្នុងគោលបំណងដើម្បីបង្កើនតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ គឺត្រូវមានការបែងចែកមុខងារ ភារកិច្ច និងការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់នៅកម្រិតគ្រប់គ្រងនិងកម្រិតអនុវត្ត។ ការផ្ដល់សិទ្ធិអំណាចនិងការទទួលខុសត្រូវក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈទៅឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវធ្វើឡើងជាបន្តបន្ទាប់ តាមរយៈការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេច ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្មរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ចាប់ផ្ដើមក្នុងជំហានទី១ នៅឆ្នាំ២០១៩, ជំហានទី២ នៅឆ្នាំ២០២២, និងជំហានទី៣ ដែលជាជំហានចុងក្រោយនៅឆ្នាំ២០២៥ នៅពេលមានគណនេយ្យភាពច្បាស់លាស់។ ការប្រគល់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្មនេះមិនអនុវត្តចំពោះមុខសញ្ញាលទ្ធកម្មមួយចំនួន ដែលមានទំហំធំ មានចរិតជាយុទ្ធសាស្ត្រមានលក្ខណៈបច្ចេកទេសដោយឡែកសម្រាប់ការគ្រប់គ្រង និង/ឬមានវេទយិតភាពខ្ពស់ ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ស្របតាមទិសដៅនេះ នៅដំណាក់កាលដំបូងនៅឆ្នាំ២០២២ដល់ឆ្នាំ២០២៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្ទេរមន្ត្រីដែលមានជំនាញលទ្ធកម្មសាធារណៈឱ្យទៅចូលរួមក្នុងក្របខ័ណ្ឌអភិបាលថវិកានៅអមក្រសួងស្ថាប័ន។ ជាទិសដៅក្នុងការកែទម្រង់ទៅថ្ងៃអនាគត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្ទេរមុខងារលទ្ធកម្ម ដែលជាផ្នែកមួយនៃអភិបាលថវិកាទៅអមជាមួយក្រសួង ស្ថាប័ន នៅពេលដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្លាយជានិយ័តករពេញលេញ។

ទន្ទឹមនឹងការផ្ដល់សិទ្ធិអំណាចនិងការទទួលខុសត្រូវក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈទៅឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់គឺ ត្រូវពង្រឹងការគ្រប់គ្រងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ពង្រឹងការធ្វើសវនកម្មកិច្ចលទ្ធកម្ម និងរៀបចំបង្កើតប្រព័ន្ធស្តង់ដារតម្លៃ សម្រាប់ធានាតម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង ព្រមទាំងធានាបាននូវតម្លៃសាច់ប្រាក់ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។ ចាប់ពីឆ្នាំ២០១៩ តទៅ ត្រូវពង្រឹងការគ្រប់គ្រងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងពង្រឹងការធ្វើសវនកម្មកិច្ចលទ្ធកម្ម។ ការសិក្សាស្រាវជ្រាវនិងរៀបចំបង្កើតប្រព័ន្ធស្តង់ដារតម្លៃនឹងចាប់ផ្ដើមពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២ ហើយនឹងត្រូវដាក់ឱ្យអនុវត្តសាកល្បងជាបណ្ដើរៗ ចាប់ពីឆ្នាំ២០២៣ តទៅ។ ចំពោះរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញរាជធានី ខេត្តតាមគំរូថ្មី នឹងត្រូវរៀបចំនិងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២២។

### ៤.២.៣ ការត្រួតពិនិត្យនិងការវាយតម្លៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

ក្នុងទិសដៅដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងកិច្ចលទ្ធកម្មសាធារណៈចាំបាច់ត្រូវមានក្របខ័ណ្ឌច្បាប់និងនីតិវិធីច្បាស់លាស់សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំកែលម្អសៀវភៅណែនាំស្តីពីការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ។

ចាប់ពីឆ្នាំ២០២៣តទៅ គឺត្រូវពង្រីកការធ្វើសវនកម្មលើការអនុវត្តកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ បន្ថែមពីលើការធ្វើសវនកម្មលើការអនុវត្តកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិការដ្ឋ។

### ៤.២.៤ ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្ដឹងតវ៉ា

បច្ចុប្បន្ន ការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្មត្រូវធ្វើឡើងដោយផ្អែកតាមអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីបែបបទនិងនីតិវិធីនៃការប្ដឹង និងការដោះស្រាយបណ្ដឹងតវ៉ា។ ដើម្បីធានាបាននូវឯករាជ្យភាពនៃយន្តការដោះស្រាយបណ្ដឹងតវ៉ានេះ គឺចាំបាច់ត្រូវពិនិត្យឡើងវិញដើម្បីកែលម្អបន្ថែមលើក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តបច្ចុប្បន្ននិងបង្កើតយន្តការដោះស្រាយបណ្ដឹងតវ៉ានេះឱ្យមានភាពឯករាជ្យ។ ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២២ ត្រូវរៀបចំកែលម្អអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីបែបបទនិងនីតិវិធីនៃការប្ដឹង និងការដោះស្រាយបណ្ដឹងតវ៉ា ដោយបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ។

### ៤.២.៥ មេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់

#### ៤.២.៥.១ ការកែលម្អក្របខ័ណ្ឌគតិយុត្តនៃលទ្ធកម្មសាធារណៈ

ផ្អែកតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ការសិក្សាឡើងវិញគ្រប់ទិដ្ឋភាពនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១២ នឹងត្រូវចាប់ផ្តើមសិក្សាពិនិត្យឡើងវិញជាបណ្តើរៗចាប់ពីឆ្នាំ២០១៩ ដើម្បីធ្វើវិសោធនកម្មឱ្យរួចរាល់នៅឆ្នាំ២០២០។ ដូចនេះ ការពិនិត្យសិក្សាឡើងវិញលើច្បាប់ស្តីពីលទ្ធកម្មសាធារណៈនឹងត្រូវធ្វើឡើងជាបណ្តើរៗពីឆ្នាំ២០១៩ ហើយនឹងត្រូវធ្វើវិសោធនកម្មឱ្យបានរួចរាល់នៅឆ្នាំ២០២១។

ការរៀបចំកែសម្រួលឬរៀបចំថ្មីនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់អនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈក្រោយធ្វើវិសោធនកម្មរួច ត្រូវធ្វើឡើងចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៣ ។

ចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤ ត្រូវរៀបចំបង្កើត "សៀវភៅណែនាំស្តីពីលទ្ធកម្មសាធារណៈ (Public Procurement Manual)" ដែលរួមបញ្ចូលនូវគោលការណ៍ វិធាន និងនីតិវិធីលទ្ធកម្មសម្រាប់គ្រប់គ្រងនិងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

#### ៤.២.៥.២ ការសិក្សាអំពីការប្រើប្រាស់លទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP)

ជាទិសដៅ ដើម្បីជំរុញឱ្យប្រព័ន្ធលទ្ធកម្មសាធារណៈអាចប្រព្រឹត្តទៅកាន់តែមានតម្លាភាពនិងប្រសិទ្ធភាព ការសិក្សារៀនសូត្រនិងដកស្រង់បទពិសោធន៍ពីបណ្តាប្រទេសក្នុងតំបន់និងពិភពលោក ដែលបាននិងកំពុងអនុវត្តកិច្ចលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិចជោគជ័យនឹងត្រូវចាប់ផ្តើមពីឆ្នាំ២០២០ តទៅ ដើម្បីប្រមូលធាតុចូលសម្រាប់រៀបចំផែនការសកម្មភាព ដើម្បីកសាងក្របខ័ណ្ឌគតិយុត្តក្នុងការបង្កើតលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) ដែលជាផ្នែកមួយនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ ទន្ទឹមនេះ ក៏ត្រូវពង្រីកការអនុវត្តនូវមុខងារលទ្ធកម្មមួយចំនួនបន្ថែមទៀតទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលរួមមានៈ ការគ្រប់គ្រងផែនការលទ្ធកម្ម ការគ្រប់គ្រងការចុះបញ្ជីអ្នកដេញថ្លៃ ការគ្រប់គ្រងកិច្ចសន្យាការប្រគល់ទទួលជាដើម។

#### ៤.២.៥.៣ ការកសាងសមត្ថភាព

ដោយសារមានការផ្លាស់ប្តូររបៀបរបបនិងប្រព័ន្ធនៃការគ្រប់គ្រងនិងការអនុវត្តការងារដែលអាចកើតចេញពីការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ នៅពេលដែលកម្មវិធីកែទម្រង់ត្រូវបានអនុវត្តដោយពេញលេញនៅគ្រប់ដំណាក់កាលនោះ ចាំបាច់ត្រូវរៀបចំនិងអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាលនិងវិក្រឹត្យការជំនាញវិជ្ជាជីវៈពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈជូនមន្ត្រីគ្រប់គ្រងនិងអនុវត្តលទ្ធកម្មសាធារណៈ ដើម្បីឱ្យមន្ត្រីទាំងនោះមានលទ្ធភាពនិងសមត្ថភាពគ្រប់គ្រាន់ទុកជាមុនដើម្បីសម្របខ្លួនទៅនឹងបរិយាកាសនិងបរិបទការងារថ្មីនៅស្ថាប័នរបស់ខ្លួន។ ក្នុងទិសដៅដើម្បីគាំទ្រដល់សកម្មភាពនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ត្រូវរៀបចំផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកលទ្ធកម្មសាធារណៈសម្រាប់បំពេញនូវតម្រូវការនៃជំនាញវិជ្ជាជីវៈក្នុងការអនុវត្តការងារកែទម្រង់។

គោលដៅរួមនៃការកសាងសមត្ថភាពមន្ត្រីរាជការលើជំនាញលទ្ធកម្មសាធារណៈ គឺដើម្បីពង្រឹងនិងពង្រីកសមត្ថភាពជំនាញវិជ្ជាជីវៈ ដល់មន្ត្រីលទ្ធកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តតួនាទីភារកិច្ចពាក់ព័ន្ធនឹងការងារលទ្ធកម្មសាធារណៈ ហើយការកសាងសមត្ថភាពនេះនឹងត្រូវធ្វើឡើងចាប់ពីឆ្នាំ២០១៩ តទៅ។

## ៤.៣ ការវិភាគនិងការគ្រប់គ្រងហានិភ័យ

### ៤.៣.១ ការវិភាគហានិភ័យ

ជាការពិត ការឈានទៅសម្រេចគោលបំណងនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈត្រូវការពេលវេលានិងត្រូវធ្វើដំណើរទៅលើផ្លូវដ៏វែងឆ្ងាយ។ ដូច្នេះ កិច្ចការសំខាន់ គឺត្រូវកំណត់ពីជំហានសម្រាប់អនុវត្តដំណើរការកែទម្រង់នេះជាពិសេសត្រូវវាយតម្លៃថា តើគោលដៅដែលបានកំណត់រួចហើយ ទទួលបានជោគជ័យហើយឬយ៉ាងណា មុននឹងបន្តឈានទៅអនុវត្តជំហានបន្តបន្ទាប់ទៀត។ ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ គឺជាកិច្ចការដែលមានវិសាលភាពធំនិងមានភាពប្រទាក់ក្រឡាជាមួយនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ប្រព័ន្ធថវិកា និងកំណែទម្រង់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលរួមមានៈ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការកែទម្រង់រដ្ឋបាលសាធារណៈដែលជាហេតុនាំឱ្យការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនេះអាចជួបប្រទះនូវហានិភ័យ។

លើសពីនេះរចនាសម្ព័ន្ធគាំទ្រ កិច្ចសម្របសម្រួល និងកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធក្នុងការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានដែលធ្វើឱ្យការអនុវត្តយុទ្ធសាស្ត្រកែទម្រង់នេះទទួលបានជោគជ័យ។ ការកសាងសមត្ថភាពតួអង្គពាក់ព័ន្ធដើម្បីគ្រប់គ្រងការផ្លាស់ប្តូរនៅក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រកែទម្រង់គឺជាកិច្ចការចាំបាច់ដើម្បីដោះស្រាយនូវហានិភ័យដែលអាចកើតមានឡើងជាយថាហេតុ។

ហានិភ័យចម្បងៗដែលអាចកើតមានឡើងក្នុងការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈរួមមាន៖ កង្វះឆន្ទៈរបស់ថ្នាក់ដឹកនាំនិងមន្ត្រីបច្ចេកទេសក្នុងការទទួលយកនិងអនុវត្តតាមការកែទម្រង់ ភាពមិនស្របគ្នានៃបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលបណ្តាលមកពីការពន្យារពេលនៃការរៀបចំនិងវិសោធនកម្មនៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដោយសារកត្តាផ្សេងៗ កង្វះកិច្ចសម្របសម្រួល កិច្ចសហប្រតិបត្តិការ ការគាំទ្រ និងសមត្ថភាពរបស់តួអង្គពាក់ព័ន្ធក្នុងការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ និងការពន្យារពេលវេលានៃការអនុវត្តកម្មវិធីកែទម្រង់នៅក្នុងការដ្ឋានណាមួយដែលមានភាពប្រទាក់ក្រឡាគ្នា។

### ៤.៣.២ ការគ្រប់គ្រងហានិភ័យ

ដើម្បីបង្ការនិងដោះស្រាយនូវហានិភ័យដែលអាចកើតឡើងជាយថាហេតុ ក្នុងការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈគឺត្រូវមានវិធានដូចខាងក្រោម៖

- ផ្សព្វផ្សាយ អប់រំ និងបញ្ជ្រាបការយល់ដឹងអំពីអត្ថប្រយោជន៍រួម ដែលកើតចេញពីកម្មវិធីកែទម្រង់ក្នុងគោលដៅដើម្បីឱ្យថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធ គាំទ្រនិងចូលរួមអនុវត្តយុទ្ធសាស្ត្រកែទម្រង់
- កំណត់ផែនការសកម្មភាពឱ្យបានច្បាស់លាស់នៃការធ្វើវិសោធនកម្មនិងកែលម្អលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- បង្កើតយន្តការសម្របសម្រួលឱ្យបានច្បាស់លាស់នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- កំណត់ពេលវេលាឱ្យបានច្បាស់លាស់តាមលំដាប់លំដោយ និងចៀសវាងភាពជាន់គ្នា និងកង្វះធនធានដែលជាឧបសគ្គរាំងស្ទះដល់ការអនុវត្តពន្លឿនពេលវេលាក្នុងការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ជាយថាហេតុ
- បង្កើតផែនការសកម្មភាពកសាង និងអភិវឌ្ឍធនធានមនុស្ស ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រកែទម្រង់
- បង្កើតឱ្យមានប្រព័ន្ធដាក់ពិន័យ និងទោសទណ្ឌ ដល់អ្នកមិនអនុវត្តតាម និងប្រព្រឹត្តខុស និងការលើកទឹកចិត្តដល់មន្ត្រីអនុវត្តបានល្អក្នុងការអនុវត្តយុទ្ធសាស្ត្រកែទម្រង់។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលស្គាល់ថា ដើម្បីសម្រេចគោលបំណងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥ ត្រូវការពេលវេលានិងត្រូវធ្វើដំណើរនៅលើផ្លូវដ៏វែងឆ្ងាយ និងត្រូវពុះពារឆ្លងកាត់ការខិតខំប្រឹងប្រែងថែមទៀត។ ជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់នេះ គឺអាស្រ័យលើលទ្ធផលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ប្រព័ន្ធថវិកា រួមទាំងការកែទម្រង់សំខាន់ៗផ្សេងទៀតរបស់រាជរដ្ឋាភិបាល រួមមាន÷ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនិងការកែទម្រង់រដ្ឋបាលសាធារណៈ ព្រមទាំងការចូលរួមអនុវត្តយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធរួមមាន÷ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ក្រសួងស្ថាប័នផងដែរ។

ការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ គឺដើម្បីកែលម្អប្រព័ន្ធលទ្ធកម្មសាធារណៈឱ្យក្លាយជាប្រព័ន្ធមួយកាន់តែមានភាពជឿទុកចិត្ត ប្រសិទ្ធភាព ការប្រកួតប្រជែង និងស្របតាមបទដ្ឋាន និងឧត្តមានុវត្តន៍អន្តរជាតិ ព្រមទាំងរួមចំណែកពង្រឹងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់រយៈពេលវែង សំដៅជំរុញកំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផលនៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ ជាពិសេសរួមចំណែកអនុវត្តតាមចក្ខុវិស័យវែងឆ្ងាយនិងបំណងប្រាថ្នាដ៏ឧត្តុងឧត្តមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និងការកសាងបាននូវសង្គមមួយប្រកបដោយសុខដុមរមនាទាំងក្នុងសង្គមជាតិនិងទាំងក្នុងក្រុមគ្រួសារ។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ នឹងរួមចំណែកដល់ការបង្កើនតម្លាភាពនិងប្រសិទ្ធភាព នៃការគ្រប់គ្រងចំណាយសាធារណៈរបស់រដ្ឋាភិបាលដែលផ្តោតអាទិភាពកាន់តែខ្លាំងលើកំណើនសេដ្ឋកិច្ចនៃការទ្រទ្រង់ វិស័យសង្គមកិច្ច សម្រាប់បម្រើឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាពលរដ្ឋទាំងមូល។

ចុងក្រោយ ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ត្រូវបានចាត់ទុកជាឯកសាររស់ ដែលជាកម្មវត្ថុនៃការកែសម្រួលជាបន្តបន្ទាប់ទៅតាមបរិការណ៍ថ្មី ដែលមិនអាចព្យាករណ៍ត្រឹមត្រូវបានទាំងស្រុងឡើយ។

## ឧបសម្ព័ន្ធទី១
## បទពិសោធន៍អំពីប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ប្រទេសហ្វីលីពីននិងបារាំង

### ១.១ ប្រទេសហ្វីលីពីន

ប្រព័ន្ធថវិកានៅប្រទេសហ្វីលីពីនត្រូវបានអនុវត្តតាមប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម។ មុនឆ្នាំ២០០៣ ការគ្រប់គ្រងលទ្ធកម្មសាធារណៈរបស់ប្រទេសហ្វីលីពីនត្រូវបានអនុវត្តតាមប្រព័ន្ធមិនច្បាស់លាស់នៅរាយប៉ាយមិនប្រមូលផ្តុំ ហើយគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិទាំងឡាយមិនមានសង្គតិភាពរវាងគ្នា និងមិនគោរពតាមស្តង់ដារអន្តរជាតិ ខ្វះតម្លាភាព និងខ្វះយន្តការប្រតិតុល្យការ (Check and Balance)។ តាមការវាយតម្លៃរបស់ភ្នាក់ងារលទ្ធកម្មសម្រាប់វាយតម្លៃសូចនាករសមិទ្ធកម្ម និងអនុលោមភាព (Agency Procurement Compliance and Performance Indicator-APCPI) បានបង្ហាញពីបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈរួមមាន÷ រៀបចំផែនការលទ្ធកម្ម ៣៥% ខកខានមិនអនុវត្តលទ្ធកម្ម ១៧% ពន្យារពេលក្នុងដំណើរការពិនិត្យនិង/ឬការពិនិត្យសម្រេច ១០% មិនមានបុគ្គលិកគ្រប់គ្រាន់ ៨% បញ្ហានៅក្រសួងថវិកានិងគ្រប់គ្រង (អង្គភាពលទ្ធកម្ម ៣% មានការចូលរួមពីអ្នកអង្កេតការ ៣% ការគ្រប់គ្រងរបាយការណ៍មិនសូវល្អ ១%) និងមានការបកស្រាយច្បាប់ខុសគ្នា។ ផ្តើមចេញពីបញ្ហាទាំងនេះ ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់ហ្វីលីពីនត្រូវបានធ្វើឡើងនៅឆ្នាំ២០០៣ ដោយផ្អែកលើគោលការណ៍អភិបាលកិច្ចល្អក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈក្នុងនោះរួមមាន÷ តម្លាភាព គណនេយ្យភាព ការប្រកួតប្រជែង និងប្រសិទ្ធភាព ព្រមទាំងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ជាមួយនឹងការកំណត់គោលនយោបាយប្រព័ន្ធលទ្ធកម្មតែមួយ ដោយគ្របដណ្តប់ទាំងថវិកាជាតិ និងថវិកាដែលហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ លើកលែងតែមានចែងក្នុងសន្ធិសញ្ញាដោយឡែក ឬត្រូវគោរពតាមសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិដោយឡែកណាមួយ។

ច្បាប់លទ្ធកម្មសាធារណៈឆ្នាំ២០០៣ ដែលត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ២០១៧ បានបែងចែកសិទ្ធិអំណាច និងការទទួលខុសត្រូវដាច់ពីគ្នារវាងស្ថាប័នគ្រប់គ្រង (និយ័តករ) និងស្ថាប័នអនុវត្តលទ្ធកម្ម (ប្រតិបត្តិករ)។ ហ្វីលីពីនបានបង្កើតក្រុមប្រឹក្សាគោលនយោបាយលទ្ធកម្មសាធារណៈរដ្ឋាភិបាល (Government Procurement Policy Board-GPPB) ដែលដើរតួជានិយ័តករ ហើយមានមុខងារសំខាន់បីគឺ÷ (១). រៀបចំគោលនយោបាយលទ្ធកម្មសាធារណៈ (២). បណ្តុះបណ្តាលជំនាញលទ្ធកម្មដល់ស្ថាប័នអនុវត្តលទ្ធកម្ម និង (៣). ត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តលទ្ធកម្ម។ ក្រុមប្រឹក្សាគោលនយោបាយលទ្ធកម្មសាធារណៈរដ្ឋាភិបាលស្ថិតក្រោមក្រសួងថវិកានិងគ្រប់គ្រង ដោយមានសមាសភាពចូលរួមពីក្រសួងស្ថាប័នសំខាន់ៗចំនួន១២ រួមទាំងភ្នាក់ងារសវនកម្ម អង្គភាពប្រឆាំងអំពើពុករលួយ និងតំណាងវិស័យឯកជនផងដែរ។ ក្រុមប្រឹក្សាគោលនយោបាយនេះក៏មានការិយាល័យគាំទ្រផ្នែកបច្ចេកទេស (Technical Support Office-TSO) ដែលប្រមូលផ្តុំនូវជំនាញបច្ចេកទេសសម្រាប់គាំទ្រដល់កិច្ចដំណើរការលទ្ធកម្មសាធារណៈ។

ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមផែនការលទ្ធកម្ម។ ផែនការលទ្ធកម្មត្រូវបានរៀបចំឡើង តាមស្តង់ដាររបស់ក្រុមប្រឹក្សាគោលនយោបាយលទ្ធកម្មសាធារណៈរដ្ឋាភិបាល និងអនុម័តដោយប្រធានស្ថាប័នអនុវត្តលទ្ធកម្ម (Head of Procurement Entity - HOPE)។

ក្រៅពីស្ថាប័នអនុវត្តលទ្ធកម្មនៅក្រសួងថវិកានិងគ្រប់គ្រង ក៏មានស្ថាប័នមួយផ្សេងទៀតក្រៅពីក្រុមប្រឹក្សាគោលនយោបាយលទ្ធកម្មសាធារណៈរដ្ឋាភិបាល ដែលហៅថាស្ថាប័នផ្តល់សេវាលទ្ធកម្ម (Procurement Service-PS) ដែលជាស្ថាប័នស្វយ័ត ហើយបំពេញមុខងារជាអ្នកជួយផ្នែកបច្ចេកទេសនិងជាអ្នកធ្វើលទ្ធកម្មជំនួសឱ្យស្ថាប័នអនុវត្តលទ្ធកម្មលើមុខទំនិញប្រើប្រាស់ទូទៅ ដែលមានប្រមាណជាង ៣០០មុខទំនិញ។ ចំពោះស្ថាប័នអនុវត្តលទ្ធកម្មសាមីដែលមិនទាន់មាន

ជំនាញលទ្ធកម្ម ឬមិនចង់ពាក់ព័ន្ធនឹងកិច្ចការលទ្ធកម្ម ដោយចង់ផ្តោតតែលើការងារជំនាញរបស់អង្គភាពខ្លួនអាចស្នើឱ្យស្ថាប័នផ្តល់សេវាលទ្ធកម្មនេះធ្វើលទ្ធកម្មជំនួសឱ្យ ដោយត្រូវបង់កម្រៃសេវាកម្រិតអតិបរមាចំនួន ៤ %។ ស្ថាប័នផ្តល់សេវាលទ្ធកម្មមានមុខងាររ៉ាប់រងលើការដេញថ្លៃមានឃ្លាំងស្តុកទំនិញនៅស្នាក់ការកណ្តាល តាមតំបន់ និងតាមដេប៉ូខេត្ត ព្រមទាំងមានសេវាដឹកជញ្ជូនចែកចាយជូនស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ កម្រៃសេវាទទួលបាន ៤% ត្រូវបានប្រើប្រាស់សម្រាប់ការលើកទឹកចិត្ត និងដំណើរការរបស់ស្ថាប័នផ្តល់សេវាលទ្ធកម្ម។ សម្រាប់មុខទំនិញប្រើប្រាស់ទូទៅ ស្ថាប័នផ្តល់សេវាលទ្ធកម្មធ្វើការដេញថ្លៃជាកញ្ចប់រួមទូទាំងប្រទេស ដោយផ្អែកតាមផែនការលទ្ធកម្មសំយោគរួម។ ចំណែកឯមុខទំនិញដែលមិនប្រើប្រាស់ទូទៅវិញ ស្ថាប័នផ្តល់សេវាលទ្ធកម្មក៏អាចធ្វើការដេញថ្លៃជំនួសឱ្យបានដែរ ដោយត្រូវពិភាក្សាលម្អិតតាមករណីនៃគម្រោងនីមួយៗទៅតាមការចង់បានរបស់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។

ជាបណ្តើរៗ ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់មានទំនោរទៅរកសេវាលទ្ធកម្មរបស់ស្ថាប័នផ្តល់សេវាលទ្ធកម្មកាន់តែច្រើនឡើងៗ ដោយសារការឱ្យស្ថាប័ននេះធ្វើលទ្ធកម្មជំនួសឱ្យមានប្រសិទ្ធភាពជាង។ ម្យ៉ាងទៀត ការធ្វើទំនើបនីយកម្មប្រព័ន្ធលទ្ធកម្មសាធារណៈបានអនុញ្ញាតឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់នៅទូទាំងហ្វីលីពីនធ្វើការផ្សព្វផ្សាយរាល់ដំណើរការកិច្ចលទ្ធកម្មលើប្រព័ន្ធគ្រប់គ្រងលទ្ធកម្មរដ្ឋាភិបាលតាមអេឡិចត្រូនិច (Philippines Government Electronic Procurement System-PhilGEPS)។ ការអនុវត្តប្រព័ន្ធលទ្ធកម្មរដ្ឋាភិបាលតាមអេឡិចត្រូនិចនេះត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តសាកល្បងនៅស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់មួយចំនួននៅឆ្នាំ២០០០ និងដាក់ឱ្យប្រើប្រាស់ពេញលេញនៅឆ្នាំ២០០៦។ ការអនុវត្តកិច្ចលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិចមានមុខងារសំខាន់ចំនួន៤ គឺ÷ (១).ក្តារខៀនព្រឹត្តិបត្រព័ត៌មានអេឡិចត្រូនិច (Electronic Bulletin Board) (២).កន្លែងសម្រាប់ឱ្យអ្នកពាក់ព័ន្ធនឹងលទ្ធកម្មរដ្ឋាភិបាលចុះបញ្ជី (៣).ផ្តល់ព័ត៌មានដោយស្វ័យប្រវត្តិពីឱកាសនៃការចូលរួមដេញថ្លៃ និង (៤).គេហទំព័រផ្លូវការសម្រាប់រដ្ឋាភិបាលទទួលឯកសារជាលក្ខណៈអេឡិចត្រូនិចផ្លូវការ។

ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅហ្វីលីពីន គឺនៅពេលប្រកាសផ្សព្វផ្សាយអំពីការដេញថ្លៃត្រូវបង្ហាញឱ្យអ្នកដេញថ្លៃឃើញពីតម្លៃនៃគម្រោងដែលត្រូវដេញថ្លៃនោះតែម្តង ហើយបន្ថែមពីលើនេះបានអនុញ្ញាតឱ្យមានអ្នកសង្កេតការចូលរួមក្នុងដំណើរការនៃកិច្ចលទ្ធកម្មសាធារណៈ ហើយអ្នកសង្កេតការមានសមាសភាពមកពីគណៈកម្មការសវនកម្ម វិស័យឯកជន ភាគីពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មរដ្ឋាភិបាលដែលបានទទួលស្គាល់ និងអង្គការមិនមែនរដ្ឋាភិបាល។ អ្នកសង្កេតការទាំងនោះអាចចូលរួមបានក្នុងគ្រប់ដំណាក់កាលនៃកិច្ចដំណើរការលទ្ធកម្មសាធារណៈ ពោលគឺចាប់ពីដំណាក់កាលនៃការបើកសំណើដេញថ្លៃរហូតដល់ដំណាក់កាលវាយតម្លៃប្រគល់កិច្ចសន្យា។

ចំពោះកិច្ចសន្យាលទ្ធកម្ម គឺត្រូវធ្វើឡើងជារូបិយប័ណ្ណជាតិរបស់ហ្វីលីពីន និងក្នុងតម្លៃថេរ (Fixed price)។ ក្នុងករណីមានការប្រែប្រួលតម្លៃវិញ គឺតម្រូវឱ្យមានការអនុម័តពីក្រុមប្រឹក្សាគោលនយោបាយលទ្ធកម្មរដ្ឋាភិបាល ឬការកែប្រែដោយមានចែងក្នុងកិច្ចព្រមព្រៀង។

ចំណែកឯយន្តការនៃការប្តឹងតវ៉ារបស់ហ្វីលីពីនគឺ ប្រសិនបើអ្នកប្តឹងណាមួយចង់ប្តឹងតវ៉ា ជំហានដំបូងត្រូវរៀបចំលិខិតប្តឹងទៅគណៈកម្មាធិការវាយតម្លៃសំណើដេញថ្លៃ។ គណៈកម្មាធិការវាយតម្លៃសំណើដេញថ្លៃមានរយៈពេល ០៧ (ប្រាំពីរ)ថ្ងៃ ក្នុងការដោះស្រាយបណ្តឹងតវ៉ា។ ក្នុងករណី អ្នកប្តឹងមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការនេះ អ្នកប្តឹងអាចប្តឹងទៅប្រធានស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ យន្តការចុងក្រោយគឺត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច។ ដំណាក់កាលប្តឹងទៅតុលាការនេះ អ្នកប្តឹងអាចទទួលបានតែសំណងជម្ងឺចិត្តតែប៉ុណ្ណោះ គឺមិនអាចប្តូរការសម្រេចប្រគល់កិច្ចសន្យាបានវិញឡើយ។ ផ្ទុយទៅវិញ ប្រសិនបើស្ថាប័នអនុវត្តលទ្ធកម្មមានភាពស្អាតស្អំអាចប្តឹងបកទៅអ្នកប្តឹងវិញផងដែរ ដើម្បីទាមទារសំណង និងដាក់អ្នកប្តឹងនោះក្នុងបញ្ជីខ្មៅផងដែរ។ ការប្តឹងតវ៉ានេះត្រូវបង់ថ្លៃសេវាលើពាក្យបណ្តឹងតាមច្បាប់កំណត់។

## ១.២ ប្រទេសបារាំង

ប្រព័ន្ធថវិកានៅប្រទេសបារាំង ត្រូវបានអនុវត្តតាមប្រព័ន្ធថវិកាសមិទ្ធកម្មនៅក្រោមច្បាប់អង្គការស្ដីពីប្រព័ន្ធថវិកាឆ្នាំ២០០៦។ ការគ្រប់គ្រងលទ្ធកម្មសាធារណៈត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលលទ្ធកម្មរដ្ឋ ហើយក្រុមប្រឹក្សាភិបាលនេះស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់បារាំងបាននិងកំពុងកែទម្រង់ទាំងក្របខ័ណ្ឌច្បាប់និងស្ថាប័ន ដើម្បីឱ្យមានសង្គតិភាពជាមួយបណ្ដាប្រទេសអភិវឌ្ឍន៍ និងតម្រូវតាមលក្ខខណ្ឌរបស់សហគមន៍អឺរ៉ុប។ លទ្ធផលនៃការកែទម្រង់នេះ ប្រទេសបារាំងបានរៀបចំនិងកែលម្អក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងលទ្ធកម្មសាធារណៈផ្អែកលើគោលការណ៍តម្លាភាពនិងអភិបាលកិច្ចល្អ ដោយបានរៀបចំនិងដាក់ឱ្យអនុវត្តច្បាប់សម្រាប់គ្រប់គ្រងលទ្ធកម្មសាធារណៈនៅឆ្នាំ២០១៦ សម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅទូទាំងប្រទេសតាមប្រព័ន្ធតែមួយ។ ទិសដៅនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់បារាំង គឺឆ្ពោះទៅរកការអនុវត្តលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP)។ បច្ចុប្បន្ន ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់បារាំងបាននិងកំពុងអនុវត្តលទ្ធកម្មរដ្ឋាភិបាលប្រព័ន្ធអេឡិចត្រូនិច (e-GP) ទាំងស្រុង នៅគ្រប់ដំណាក់កាលនៃកិច្ចលទ្ធកម្មសាធារណៈតែម្ដង គឺមានន័យថាចាប់ពីដំណាក់កាលផ្សព្វផ្សាយអំពីការដេញថ្លៃរហូតដល់ដំណាក់កាលវាយតម្លៃប្រគល់កិច្ចសន្យា ដោយពុំមានការធ្វើលទ្ធកម្មតាមរយៈការប្រើប្រាស់ក្រដាស់ស្នាមទៀតឡើយ។ ការធ្វើទំនើបកម្មប្រព័ន្ធលទ្ធកម្មសាធារណៈរបស់បារាំង គឺបង្កើតឱ្យមានស្ថាប័នទទួលបន្ទុកអនុវត្តកិច្ចលទ្ធកម្មលើទំនិញ សេវាកម្ម និងសេវាទីប្រឹក្សាទាំងអស់ជូនស្ថាប័នអនុវត្តលទ្ធកម្ម ដែលមានឈ្មោះថា សហព័ន្ធប្រមូលផ្ដុំទំនិញសាធារណៈ (Union des Groupements d'Achats Publics-UGAP) ជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តកិច្ចលទ្ធកម្មស្ទើរតែទាំងអស់ (លើកលែងតែការសាងសង់ និងការជួសជុលធំៗ)ប៉ុណ្ណោះ។ ស្ថាប័ន UGAP គឺត្រូវបានបង្កើតឡើងដោយរដ្ឋ និងជាស្ថាប័នស្វយ័តស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពមកពីក្រសួងហិរញ្ញវត្ថុ និងក្រសួងអប់រំ។ ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់នានាបានស្នើឱ្យ UGAP ធ្វើការដេញថ្លៃលើទំនិញ សេវាកម្ម និងសេវាទីប្រឹក្សា ជំនួសឱ្យខ្លួន ដោយសារពួកគេមិនសូវមានជំនាញ និងមិនមានពេលវេលាគ្រប់គ្រាន់។ តាមរយៈការដេញថ្លៃដែលធ្វើឡើងដោយ UGAP នេះ បានកសាងនូវទំនុកចិត្តនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈពីស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់និងក្រុមហ៊ុនផ្គត់ផ្គង់ តាមរយៈការធានាបាននូវតម្លាភាពគណនេយ្យភាព ប្រសិទ្ធភាព គុណភាព និងការទូទាត់ ព្រមទាំងទទួលបានទំនិញនិងសេវាទាន់ពេលវេលា។ ការដេញថ្លៃជំនួសនេះ ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវបង់កម្រៃសេវាកម្រិតអតិបរមាចំនួន ៤% នៃតម្លៃកិច្ចសន្យាទៅឱ្យ UGAP សម្រាប់ជាប្រាក់ចំណូលដើម្បីទ្រទ្រង់ប្រតិបត្តិការរបស់ខ្លួន។ ប៉ុន្តែ UGAP មិនរ៉ាប់រងលើការដឹកជញ្ជូននិងឃ្លាំងស្តុកទំនិញដូចស្ថាប័នផ្តល់សេវាលទ្ធកម្ម (PS) នៅហ្វីលីពីនឡើយ ព្រោះបន្ទាប់ពីទទួលបានការបញ្ជាទិញពីស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ UGAP ត្រូវធ្វើការដេញថ្លៃជាមួយអ្នកផ្គត់ផ្គង់ ដោយតម្រូវឱ្យការប្រគល់ទទួលទំនិញត្រូវធ្វើឡើងនៅសាមីស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់តែម្តង។

ចំពោះកិច្ចសន្យាលទ្ធកម្ម គឺត្រូវធ្វើឡើងជារូបិយប័ណ្ណរបស់សហគមន៍អឺរ៉ុប និងក្នុងតម្លៃថេរ (Fixed price)។ ចំណែកឯយន្តការនៃការប្ដឹងតវ៉ារបស់បារាំង ប្រសិនបើអ្នកប្ដឹងចង់ប្ដឹងតវ៉ា គឺត្រូវប្ដឹងទៅតុលាការគណនេយ្យ ដោយសារតុលាការនេះមានសមត្ថកិច្ចដោះស្រាយនូវរាល់បណ្ដឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធកម្ម។ ប៉ុន្តែ ជាទូទៅមិនសូវមានការប្ដឹងតវ៉ាកើតឡើងទេ ដោយសារ UGAP បានអនុវត្តការងាររបស់ខ្លួនប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

បន្ថែមពីលើនេះ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់បារាំង គឺនីតិវិធីនៃការគ្រប់គ្រងថវិកា និងកិច្ចលទ្ធកម្មសាធារណៈត្រូវបានបែងចែកច្បាស់លាស់រវាងអ្នកបញ្ជាចំណាយ (អាណាប័ក) និងអ្នកកត់ត្រាទូទាត់ (គណនេយ្យករ)។ មូលហេតុនៃការបែងចែកនេះ គឺដើម្បីទប់ស្កាត់កុំឱ្យមានការអនុវត្តនីតិវិធីច្របូកច្របល់រវាងអ្នកបញ្ជាចំណាយ និងអ្នកទូទាត់ និងកាត់បន្ថយនូវការបន្លំ ព្រមទាំងលើកកម្ពស់អភិបាលកិច្ចល្អក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ អាណាប័កជាអ្នកគ្រប់គ្រងការចំណាយរួមទាំងកិច្ចលទ្ធកម្មសាធារណៈ ចំណែកឯគណនេយ្យករ គឺជាអ្នកតាមដានធ្វើកិច្ចបញ្ជីការគណនេយ្យ និងការទូទាត់ (ជាអ្នកកាន់ថវិកាផ្ទាល់)។ ចំណែកឯការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់បារាំងនៅថ្នាក់ក្រោមជាតិ គឺបានធ្វើប្រតិភូកម្មកិច្ចលទ្ធកម្មសាធារណៈជូនទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបំពេញតួនាទីឱ្យស្របតាមការអនុវត្តប្រព័ន្ធថវិកា លើកលែងតែវិស័យអប់រំនិងសុខាភិបាល ដែលត្រូវអនុវត្តនៅថ្នាក់ជាតិ។

## ឧបសម្ព័ន្ធទី២
## ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅយុទ្ធសាស្ត្រឆ្នាំ២០២៥

| ល.រ | ការងារកែទម្រង់ | អង្គភាពទទួលខុសត្រូវអនុវត្ត | ចាប់ផ្តើម | បញ្ចប់ | គោលបំណង |
|---|---|---|---|---|---|
| I. | **ការរៀបចំនិងអនុម័តផែនការលទ្ធកម្ម** | | | | |
| ១ | ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២០១៩ | ២០១៩ | រៀបចំនិងដាក់ឱ្យអនុវត្តគោលការណែនាំបំពេញបន្ថែមស្តីពីការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ |
| | | ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ | ២០១៩ | ២០២៥ | ភ្ជាប់ផែនការលទ្ធកម្មប្រចាំឆ្នាំជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ។ |
| ២ | ការអនុម័តផែនការលទ្ធកម្មប្រចាំឆ្នាំ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់របស់រដ្ឋបាលថ្នាក់ជាតិ | ២០១៩ | ២០២៥ | ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មផ្ទាល់របស់រដ្ឋបាលថ្នាក់ជាតិត្រូវពិនិត្យនិងអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋបាល ក្រុង ស្រុក ខណ្ឌ | ២០១៩ | ២០២៥ | ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យនិងអនុម័ត ដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញរាជធានី ខេត្ត | ២០១៩ | ២០២២ | ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញរាជធានីខេត្ត ត្រូវពិនិត្យនិងអនុម័ត ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញរាជធានី ខេត្ត | ២០២៣ | ២០២៥ | ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញរាជធានីខេត្ត ត្រូវពិនិត្យនិងអនុម័តដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

| | | | | | |
|---|---|---|---|---|---|
| II. | **ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ** | | | | |
| ១ | ការធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ | ២០១៩ | ២០១៩ | ផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវក្នុងការអនុវត្តកិច្ចលទ្ធកម្មទៅឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ តាមរយៈការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេច (ជំហានទី១) |
| | | | ២០២២ | ២០២២ | ផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវក្នុងការអនុវត្តកិច្ចលទ្ធកម្មទៅឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ តាមរយៈការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេច (ជំហានទី២) |
| | | | ២០២៥ | ២០២៥ | ផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវក្នុងការអនុវត្តកិច្ចលទ្ធកម្មទៅឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ តាមរយៈការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេច (ជំហានទី៣) |
| | | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ | ២០២២ | ២០២៥ | មន្ត្រីដែលមានជំនាញលទ្ធកម្មសាធារណៈនឹងត្រូវបានផ្ទេរឱ្យទៅចូលរួមក្នុងក្របខ័ណ្ឌអភិបាលថវិកានៅអមក្រសួងស្ថាប័នជាបណ្តើរៗ។ |
| ២ | កិច្ចដំណើរការលទ្ធកម្មសាធារណៈ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២០២០ | ២០២២ | រៀបចំនិងបង្កើតប្រព័ន្ធស្តង់ដារតម្លៃសម្រាប់អនុវត្ត |
| | | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២០២៣ | ២០២៥ | អនុវត្តសាកល្បងជាបណ្តើរៗនូវប្រព័ន្ធស្តង់ដារតម្លៃ |
| | | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ | ២០២២ | ២០២២ | រៀបចំនិងដាក់ឱ្យអនុវត្តស្តង់ដាររបាយការណ៍លទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគំរូថ្មី។ |

| | | | | | |
|---|---|---|---|---|---|
| ៣ | ការពង្រឹងតម្លាភាពគណនេយ្យភាពនិងការប្រកួតប្រជែង | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ | ២០១៩ | ២០២៥ | - ពង្រឹងនិងពង្រីកការបើកចំហព័ត៌មានលទ្ធកម្មនៅលើគេហទំព័រ<br>- តាមដានការអនុវត្តកិច្ចលទ្ធកម្មឱ្យសមស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ។ |
| ៤ | ការពង្រឹងការគ្រប់គ្រងការអនុវត្តកិច្ចសន្យា | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២០២២ | ២០២២ | កែលម្អលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងការអនុវត្តកិច្ចសន្យា។ |
| III. | **ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ** | | | | |
| ១ | ការត្រួតពិនិត្យនិងវាយតម្លៃ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២០២១ | ២០២២ | កែលម្អសៀវភៅណែនាំស្តីពីការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ |
| | | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២០២៣ | ២០២៥ | ធ្វើសវនកម្មលើកិច្ចលទ្ធកម្ម ដែលប្រើប្រាស់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ បន្ថែមពីលើការធ្វើសវនកម្មលើកិច្ចលទ្ធកម្មដែលប្រើប្រាស់ថវិការដ្ឋ។ |
| IV. | **ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្តឹងតវ៉ា** | | | | |
| ១ | ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្តឹងតវ៉ា | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២០២១ | ២០២២ | កែលម្អអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីបែបបទនិងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ា ដោយបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ។ |
| V. | **មេដ្ឋារចនាសម្ព័ន្ធច្បាប់** | | | | |
| ១ | ការកែលម្អក្របខ័ណ្ឌគតិយុត្តនៃលទ្ធកម្មសាធារណៈ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២០១៩ | ២០២១ | ធ្វើវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ |
| | | | ២០២២ | ២០២៣ | រៀបចំកែសម្រួលឬរៀបចំថ្មីនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់អនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈក្រោយធ្វើវិសោធនកម្មរួច |

| | | | | | |
|---|---|---|---|---|---|
| | | | ២០២៣ | ២០២៤ | បង្កើត "សៀវភៅណែនាំស្តីពីលទ្ធកម្មសាធារណៈ (Public Procurement Manual)" ដែលរួមបញ្ចូលនូវគោលការណ៍ វិធាន និងនីតិវិធីលទ្ធកម្មសម្រាប់គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។ |
| ២ | ការសិក្សាអំពីការប្រើប្រាស់លទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២០២០ | ២០២៥ | សិក្សារៀនសូត្រ និងដកស្រង់បទពិសោធន៍ពីប្រទេសផ្សេងៗសម្រាប់រៀបចំបង្កើតលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) តាមអភិក្រមជាជំហានៗ និងជាដំណាក់កាលៗ |
| | | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២០២៥ | ២០២៥ | បង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់អនុវត្តកិច្ចលទ្ធកម្មរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច (e-GP) ឱ្យស្របតាមការវិវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ( FMIS) ។ |
| ៣ | ការកសាងសមត្ថភាពនិងបណ្តុះបណ្តាល | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ | ២០១៩ | ២០២៥ | កសាងសមត្ថភាពមន្ត្រីលទ្ធកម្មលើជំនាញលទ្ធកម្មសាធារណៈ និងជំនាញពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តតួនាទីភារកិច្ចពាក់ព័ន្ធនឹងការងារលទ្ធកម្មសាធារណៈ។ |